# សេចក្តីណែនាំសម្រាប់កម្មវិធីទិដ្ឋាការអន្តោប្រវេសន៍ចម្រុះជាតិសាសន៍ឆ្នាំ២០២៦ (DV ឆ្នាំ ២០២៦)

## ព័ត៌មានទូទៅអំពីកម្មវិធី

ជារៀងរាល់ឆ្នាំ ក្រសួងការបរទេស សហរដ្ឋអាមេរិកធ្វើការរៀបចំអោយមាននូវកម្មវិធី**ទិដ្ឋាការអន្តោប្រវេសន៍ចម្រុះជាតិសាសន៍** (DV) ដែលកំណត់ដោយសភាសហរដ្ឋអាមេរិក។ មាត្រា ២០៣ (C) នៃច្បាប់ស្តីពីអន្តោប្រវេសន៍និងសញ្ជាតិ (INA) ចែងអំពីជនអន្តោប្រវេសន៍មួយប្រភេទដែលគេឲ្យឈ្មោះថា "ជនអន្តោប្រវេសន៍ចម្រុះជាតិសាសន៍" ដែលមកពីបណ្តាប្រទេសដែលមានប្រវត្តិធ្វើអន្តោប្រវេសន៍ទៅកាន់សហរដ្ឋអាមេរិកកម្រិតទាប។ សម្រាប់ឆ្នាំ២០២៦ ទិដ្ឋាការ DV នឹងអាចមានចំនួនរហូតដល់ ៥៥,០០០ច្បាប់។ ការចុះឈ្មោះក្នុងកម្មវិធី DV គឺអាចធ្វើទៅបានដោយឥតគិតថ្លៃ ប៉ុន្តែបេក្ខជនជាប់ឈ្មោះ ដែលត្រូវបានណាត់មកសម្ភាសន៍ នឹងត្រូវតម្រូវឲ្យ<u>បង់ថ្លៃពាក្យសុំទិដ្ឋការ</u> មុននឹងដាក់ពាក្យសុំទិដ្ឋការជាផ្លូវការ ដែលពេលនោះជាពេលដែលមន្ត្រីកុងស៊ុលនឹងកំណត់ថាអ្នកមានលក្ខណៈសមស្របដើម្បីទទួលទិដ្ឋាការ ឬទេ។

បេក្ខជនដែលត្រូវបានជ្រើសរើសក្នុងកម្មវិធី ("បេក្ខជនជាប់ឈ្មោះ") ត្រូវមានលក្ខណៈសម្បត្តិដែលឆ្លើយតបទៅនឹងលក្ខន្តិកៈសាមញ្ញប៉ុន្តែតឹងរ៉ឹង ដើម្បីមានភាពសមស្របសម្រាប់ទិដ្ឋាការ DV ។ ក្រសួង ការបរទេសសហរដ្ឋអាមេរិកធ្វើការជ្រើសរើសបេក្ខជនជាប់ឆ្នោតតាមរយៈការចាប់ឈ្មោះដោយចៃដន្យលើប្រព័ន្ធកុំព្យូទ័រ។ ក្រសួងការបរទេសសហរដ្ឋអាមេរិកបែងចែកទិដ្ឋាការ DV ទៅតាមទីតាំងភូមិសាស្រ្តប្រាំមួយតំបន់ ហើយគ្មានប្រទេសណាមួយអាចទទួលបានលើសពី ៧ ភាគរយ នៃចំនួនទិដ្ឋាការ DV ដែលត្រូវបានកំណត់ក្នុងឆ្នាំណាមួយឡើយ។

សម្រាប់កម្មវិធី DV ឆ្នាំ២០២៦ ប្រជាជនដើមនៃបណ្តាប្រទេសខាងក្រោមនេះមិនអាចដាក់ពាក្យបានទេ ដោយសារមានប្រជាជនដើមលើសពី ៥០,០០០ នាក់ដែលមកពីប្រទេសទាំងនេះ បានធ្វើអន្តោប្រវេសន៍ទៅរស់នៅសហរដ្ឋអាមេរិកក្នុងរយៈពេលប្រាំឆ្នាំចុងក្រោយនេះ ក្នុងនោះមាន៖

- បង់ក្លាដេស

- ប្រេស៊ីល
- កាណាដា
- ចិន(រួមទាំងហុងកុង SAR)
- កូឡុំប៊ី
- គុយបា
- សាធារណរដ្ឋដូមីនីក
- អែលសាល់វ៉ាឌ័រ
- ហៃទី
- ហុងឌូរ៉ាស
- ឥណ្ឌា
- ចាម៉ៃកា
- ម៉ិកស៊ិក
- នីហ្សេរីយ៉ា
- ប៉ាគីស្ថាន
- ហ្វីលីពីន
- កូរ៉េខាងត្បូង
- វ៉េណេស៊ុយអេឡា
- វៀតណាម
- អ្នកដែលកើតនៅ ម៉ាកាវ និងតៃវ៉ាន់ អាចធ្វើការចុះឈ្មោះបាន។

**លើកលែង តែប្រទេសគុយបា ដែលមិនអាចដាក់ពាក្យកម្មវិធី DV-២០២៦នេះបាន**

**លក្ខណៈសម្បត្តិសម្រាប់ការដាក់ពាក្យកម្មវិធី DV នេះគ្មានការ ប្រែប្រួលពីឆ្នាំមុននោះឡើយ។**

## លក្ខណៈសម្បត្តិសម្រាប់កម្មវិធីទិដ្ឋាការអន្តោប្រវេសន៍ចម្រុះជាតិសាសន៍

- **លក្ខខណ្ឌតម្រូវទី១៖**
  ជនជាតិដើមដែលមកពីបណ្ដាប្រទេសដែលមានប្រវត្តិធ្វើអន្តោប្រវេសន៍ទៅកាន់សហរដ្ឋអាមេរិកកម្រិតទាប អាចចុះឈ្មោះបាន។

- ប្រសិនបើអ្នកមិនបានកើតនៅក្នុងប្រទេសទាំងនោះទេ មានវិធីពីរយ៉ាងទៀតដែលអ្នកអាចនឹងមានសិទ្ធិក្នុងការចុះឈ្មោះបាន។
  - តើប្តី/ប្រពន្ធរបស់អ្នកកើតនៅក្នុងប្រទេសដែលប្រជាជនដើមមានសិទ្ធិចុះឈ្មោះដែរឬទេ? ប្រសិនបើមែន អ្នកអាចចុះឈ្មោះបានដោយផ្អែកលើប្រទេសកំណើតរបស់ប្តី/ប្រពន្ធរបស់អ្នក ក្នុងករណីដែលឈ្មោះអ្នកទាំងពីរបានចុះនៅក្នុងពាក្យ ហើយត្រូវបានជ្រើសរើសជាបេក្ខជនជាប់ឈ្មោះ មានលក្ខណៈសម្បត្តិគ្រប់គ្រាន់និង ទទួលបានទិដ្ឋាការDV ព្រមទាំងចូលទៅសហរដ្ឋអាមេរិកដំណាលគ្នា។
  - តើអ្នកជាជនជាតិដើមនៃប្រទេសដែលប្រជាជនពុំមានសិទ្ធិចុះឈ្មោះ ហើយឪពុកម្តាយរបស់អ្នក មិនបានកើត ឬជាប្រជាជនរស់នៅស្របច្បាប់ក្នុងប្រទេសកំណើតរបស់អ្នកនៅពេលដែលអ្នក កើតមែនទេ? ប្រសិនបើមែន អ្នកអាចចុះឈ្មោះបានដោយផ្អែកលើប្រទេសកំណើតរបស់ឪពុកឬម្តាយរបស់អ្នក ប្រសិនបើប្រទេសនោះជាប្រទេសដែលប្រជាជនដើមមានសិទ្ធិដាក់ពាក្យ DV ឆ្នាំ ២០២៦។ សម្រាប់សេចក្តីលម្អិតស្តីពីព័ត៌មានលើលក្ខណៈសម្បត្តិនៃ DV ឆ្នាំ២០២៦ សូមចូលមើល សំណួរដែលសួរញឹកញាប់បំផុត។
- **លក្ខខណ្ឌតម្រូវទី២៖** បេក្ខជនឆ្នោត DV នីមួយៗត្រូវមានកម្រិតសិក្សាឬបទពិសោធន៍ការងារស្របតាមលក្ខខណ្ឌ នៃកម្មវិធី DV ណាមួយខាងក្រោម៖
  - យ៉ាងហោចណាស់បញ្ចប់ការសិក្សាថ្នាក់វិទ្យាល័យ ឬការសិក្សាមានតម្លៃស្មើ ដែលមានន័យថាបានបញ្ចប់ការសិក្សាដោយជោគជ័យរយៈពេល ១២ ឆ្នាំ នៃកម្រិតសិក្សាផ្លូវការថ្នាក់បឋមសិក្សានិងមធ្យមសិក្សា។

  **ឬ**

  - មានបទពិសោធន៍ការងារពីរឆ្នាំក្នុងការងារដែលតម្រូវឲ្យមានការបណ្តុះបណ្តាលឬបទពិសោធន៍យ៉ាងហោចណាស់ពីរឆ្នាំដើម្បីបំពេញការងារនោះក្នុងរយៈពេលប្រាំឆ្នាំចុងក្រោយ។ ក្រសួងការបរទេសសហរដ្ឋអាមេរិកនឹងប្រើប្រាស់ប្រព័ន្ធទិន្នន័យ **O*Net Online** របស់ក្រសួងការងារសហរដ្ឋអាមេរិក ដើម្បីកំណត់អំពីលក្ខណៈសម្បត្តិ

បទពិសោធន៍ការងារ។ សម្រាប់ព័ត៌មានបន្ថែមអំពីលក្ខណៈសម្បត្តិបទពិសោធន៍ការងារ សូមចូលមើលសំណួរដែលសួរញឹកញាប់បំផុត។

សំគាល់៖ សូមកុំដាក់ពាក្យកម្មវិធី DV ប្រសិនបើអ្នកពុំមានលក្ខណៈសម្បត្តិសមស្របទៅនឹងលក្ខខណ្ឌតម្រូវទាំងពីរខាងលើនេះ។

## រដូវកាលចុះឈ្មោះ កម្មវិធី DV ឆ្នាំ ២០២៦

បេក្ខជនត្រូវដាក់ពាក្យកម្មវិធី DV ឆ្នាំ២០២៦ តាមប្រព័ន្ធអេឡិចត្រូនិចតាមរយៈគេហទំព័រ dvprogram.state.gov ចាប់ពីថ្ងៃពុធ ទី២ ខែតុលា ឆ្នាំ២០២៤ ម៉ោង១២ថ្ងៃត្រង់ (ម៉ោងនៅសហរដ្ឋអាមេរិក) រហូតដល់ថ្ងៃអង្គារ ទី៥ ខែវិច្ឆិកា ឆ្នាំ២០២៤ ម៉ោង១២ថ្ងៃត្រង់ (ម៉ោងនៅសហរដ្ឋអាមេរិក)។ សូមកុំរង់ចាំរហូតដល់សប្តាហ៍ចុងក្រោយនៃរដូវកាលចុះឈ្មោះ ដោយសារតែអាចមានការចុះឈ្មោះច្រើន ដែលជាហេតុបណ្តាលឲ្យគេហទំព័រដំណើរការយឺត។ រាល់ការចុះឈ្មោះមិនទាន់ពេលវេលា ឬការដាក់ពាក្យជាឯកសាររូបវន្ត នឹងមិនត្រូវបានទទួលយកឡើយ។ ច្បាប់អនុញ្ញាតឲ្យបេក្ខជនម្នាក់ចុះឈ្មោះតែម្តងប៉ុណ្ណោះក្នុងរដូវកាលចុះឈ្មោះនីមួយៗ។ ក្រសួងការបរទេសសហរដ្ឋអាមេរិកប្រើប្រាស់បច្ចេកវិទ្យាទំនើបដើម្បីស្វែងរកការចុះឈ្មោះច្រើនដង។ **អ្នកដែលចុះឈ្មោះលើសពីម្តងនឹងត្រូវអស់សិទ្ធិនៅក្នុងការចូលរួមដាក់ពាក្យ។**

## ការដាក់ពាក្យតាមប្រព័ន្ធអេឡិចត្រូនិចសម្រាប់កម្មវិធី DV ឆ្នាំ ២០២៦

អ្នកអាចដាក់ពាក្យក្នុងកម្មវិធី DVតាមប្រព័ន្ធអេឡិចត្រូនិច (E-DV Entry Form ឬ DS-5501) តាមរយៈគេហទំព័រ dvprogram.state.gov។ យើងនឹងមិនទទួលពាក្យចុះឈ្មោះដែលបំពេញព័ត៌មានមិនពេញលេញ ឬពាក្យដែលផ្ញើតាមមធ្យោបាយណាផ្សេងឡើយ។ ការចុះឈ្មោះនេះគឺឥតគិតថ្លៃ។ សូមប្រើកម្មវិធីអ៊ីនធើណិត (internet browser) សេរីថ្មីពេលចុះឈ្មោះ។ កម្មវិធីអ៊ីនធើណិតស៊េរីចាស់ (ឧទាហរណ៍ Internet Explorer 8) អាចនឹងជួបបញ្ហារអាក់រអួលជាមួយនឹងកម្មវិធីឆ្នោត DV។

យើងលើកទឹកចិត្តឲ្យអ្នកចុះឈ្មោះដាក់ពាក្យ DV ដោយខ្លួនឯង ដោយមិនចាំបាច់ប្រើ "អ្នកប្រឹក្សាទិដ្ឋាការ" "ភ្នាក់ងារទិដ្ឋាការ" ឬអ្នកផ្សេងណាដែលសុំខ្លួនជួយអ្នកឡើយ។ ប្រសិនបើមានបុគ្គលណាជួយអ្នក អ្នកត្រូវតែមានវត្តមាននៅពេលចុះឈ្មោះ ដើម្បីអាចផ្តល់ព័ត៌មានដែលត្រឹមត្រូវទៅនឹងសំណួរនានា ហើយអាចរក្សាទុកនូវលេខកូតបញ្ជាក់ពិសេស (unique confirmation number) របស់អ្នក

និងសូមព្រីនចេញអេក្រង់បញ្ជាក់លេខកូតពិសេស (confirmation screen) របស់អ្នកផងដែរ។ អ្នកត្រូវតែរក្សាទំព័របញ្ជាក់និងលេខកូតបញ្ជាក់ពិសេសរបស់អ្នកជាចាំបាច់។ កន្លងមកមានភ្នាក់ងារទិដ្ឋាការគ្មានក្រមសីលធម៌ខ្លះ ដែលជួយបំពេញពាក្យឲ្យបេក្ខជនហើយៗរក្សាទុកទំព័របញ្ជាក់លេខកូតពិសេស រួចក្រោយមកក៏ទាមទារប្រាក់ពីបេក្ខជនជាថ្នូរនឹងលេខកូតបញ្ជាក់ពិសេសនោះ។ ប្រសិនបើគ្មានព័ត៌មានទាំងនេះទេ អ្នកនឹងមិនអាចចូលទៅតាមដានលទ្ធផលពីការចុះឈ្មោះរបស់អ្នកនៅក្នុងប្រព័ន្ធអ៊ិនធឺណិតបានឡើយ។ សូមប្រុងប្រយ័ត្នបើមានបុគ្គលណាម្នាក់សុំជួយរក្សាព័ត៌មាននេះជូនអ្នក។ អ្នកក៏ត្រូវរក្សាគណនីអ៊ីម៉ែលដែលបានបញ្ចូលនៅក្នុងពាក្យចុះឈ្មោះ E-DV ផងដែរ។ សូមមើល [សំណួរដែលសួរញឹកញាប់បំផុត] សម្រាប់ព័ត៌មានបន្ថែមស្តីពីការឆបោកក្នុងកម្មវិធីឆ្នោត DV ។

បន្ទាប់ពីអ្នកបានចុះឈ្មោះពេញលេញហើយ អ្នកនឹងឃើញអេក្រង់បញ្ជាក់មួយ ដែលមានឈ្មោះ និងលេខកូតបញ្ជាក់ពិសេសរបស់អ្នក។ សូមព្រីនអេក្រង់បញ្ជាក់នេះសម្រាប់ទុកជាឯកសារ។ ចាប់ពីថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០២៥ អ្នកនឹងអាចតាមដានលទ្ធផលចុះឈ្មោះរបស់អ្នកតាមរយៈ dvprogram.state.gov ដោយចុចទៅលើ *ផ្នែកលទ្ធផលចុះឈ្មោះ* (*Entrant Status Check*) ហើយបញ្ចូលលេខកូតបញ្ជាក់ពិសេស និងព័ត៌មានផ្ទាល់ខ្លួនរបស់អ្នក។ អ្នកត្រូវតែចុចលើ *ផ្នែកលទ្ធផលចុះឈ្មោះ* (*Entrant Status Check*) ដើម្បីដឹងថាអ្នកត្រូវបានជ្រើសរើសជាបេក្ខជនជាប់ឈ្មោះ DV ឆ្នាំ ២០២៦ឬអត់ ហើយ ដើម្បីមើលសេចក្តីណែនាំពីការដាក់ពាក្យបន្តទៀត ប្រសិនបើអ្នកត្រូវបានជ្រើសរើស។ រដ្ឋាភិបាលអាមេរិកនឹងមិនជូនដំណឹងដល់អ្នកដោយផ្ទាល់ឡើយ។ *Entrant Status Check* គឺជាប្រភពព័ត៌មានតែមួយគត់សម្រាប់ផ្តល់ការណែនាំស្តីពីការបន្តដំណើរការដាក់ពាក្យសុំរបស់អ្នក។ ប្រសិនបើអ្នកជាប់ឈ្មោះ ហើយដាក់ពាក្យសុំទិដ្ឋការ ព្រមទាំងឯកសារតម្រូវផ្សេងៗរួចរាល់ អ្នកត្រូវប្រើ *Entrant Status Check* ដើម្បីមើលកាលបរិច្ឆេទសម្ភាសន៍ទិដ្ឋាការអន្តោប្រវេសន៍របស់អ្នក។ សូមពិនិត្យមើល [សំណួរដែលសួរញឹកញាប់បំផុត]សម្រាប់ព័ត៌មានបន្ថែមស្តីពីដំណើរការជ្រើសរើស។

អ្នកត្រូវតែផ្តល់ព័ត៌មានខាងក្រោមដើម្បីចុះឈ្មោះ។ ការមិនផ្តល់ព័ត៌មានចាំបាច់ទាំងនេះឲ្យបានត្រឹមត្រូវ អាចធ្វើឲ្យលោកអ្នកមិនអាចចូលរួមដាក់ពាក្យកម្មវិធី DV បានឡើយ។

១. ឈ្មោះ៖ នាមត្រកូល នាមខ្លួន ពោលគឺដូចឈ្មោះក្នុងលិខិតឆ្លងដែនរបស់អ្នក។ ប្រសិនបើអ្នកមានឈ្មោះតែមួយ អ្នកត្រូវបញ្ចូលនៅក្នុងប្រអប់នាមត្រកូល។

២. ភេទ៖ ប្រុស ឬ ស្រី

៣. ថ្ងៃខែឆ្នាំកំណើត៖ ថ្ងៃ ខែ ឆ្នាំ

៤. ទីក្រុងកំណើត

៥. ប្រទេសកំណើត
ដោយដាក់ឈ្មោះប្រទេសដែលកំពុងប្រើប្រាស់បច្ចុប្បន្នសម្រាប់ទីកន្លែងដែលអ្នកកើត

៦. ប្រទេសដែលមានសិទ្ធិចុះឈ្មោះសម្រាប់កម្មវិធី DV ។
ប្រទេសដែលមានសិទ្ធិចុះឈ្មោះរបស់អ្នក ជាទូទៅដូចគ្នាទៅនឹងប្រទេសកំណើតរបស់អ្នកដែរ។ ប្រទេសដែលមានសិទ្ធិចុះឈ្មោះរបស់អ្នក មិនពាក់ព័ន្ធទៅនឹងទីកន្លែងដែលអ្នកស្នាក់នៅ ឬសញ្ជាតិរបស់អ្នកឡើយ ប្រសិនបើវាខុសពីប្រទេសកំណើតរបស់អ្នក។ ប្រសិនបើអ្នកកើតក្នុងប្រទេសដែលគ្មានសិទ្ធិចុះឈ្មោះដាក់ពាក្យទេនោះ សូមចូលទៅ សំណួរដែលសួរញឹកញាប់បំផុត ដើម្បីពិនិត្យមើលថាមានវិធីណាផ្សេងទៀតដែលអ្នកអាចមានសិទ្ធិចុះឈ្មោះដែរឬទេ។

៧. រូបថតបេក្ខជន៖ ត្រូវតែជារូបថតថ្មី (ថតក្នុងរយៈពេលប្រាំមួយខែចុងក្រោយ) របស់អ្នក ប្ដី/ប្រពន្ធអ្នក និងកូនៗអ្នកទាំងអស់។ សូមមើល បញ្ជូលរូបថតឌីជីថល សម្រាប់លក្ខខណ្ឌរូបភាពនិងបច្ចេកទេស។ អ្នកមិនចាំបាច់បញ្ចូលរូបថតសម្រាប់ប្ដី/ប្រពន្ធឬកូនដែលជាជនជាតិអាមេរិក ឬអ្នកមានសិទ្ធិរស់នៅស្របច្បាប់នៅអាមេរិកហើយនោះទេ ប៉ុន្តែបើអ្នកបញ្ចូល ក៏គ្មានទោសពៃរ៍អ្វីដែរ។

រូបថតចុះឈ្មោះកម្មវិធី DV
ត្រូវមានលក្ខខណ្ឌស្តង់ដារដូចគ្នាទៅនឹងរូបថតសុំទិដ្ឋាការអាមេរិកដែរ។ ការដាក់ពាក្យ ឬពាក្យស្នើសុំទិដ្ឋាការរបស់អ្នកអាចត្រូវបដិសេធ ប្រសិនបើរូបថតរបស់អ្នក និងក្រុមគ្រួសាររបស់អ្នកមិនត្រឹមត្រូវតាមលក្ខខណ្ឌបច្ចេកទេស ឬត្រូវបានកែប្រែតាមវិធីណាមួយ។ ការបញ្ចូលរូបថតចាស់ដែលធ្លាប់ប្រើដើម្បីចុះឈ្មោះកាលពីឆ្នាំមុននឹងខុសលក្ខខណ្ឌ ហើយនឹងត្រូវបដិសេធ។ សូមមើល បញ្ជូលរូបថតឌីជីថល (ខាងក្រោម) សម្រាប់ព័ត៌មានបន្ថែម។

៨. អាសយដ្ឋានប្រៃសណីយ៍ - អ្នកទទួល

- អាសយដ្ឋានបន្ទាត់ទី ១



SENSITIVE BUT UNCLASSIFIED

- អាសយដ្ឋានបន្ទាត់ទី ២ ទីក្រុង
- ស្រុក/តំបន់/ប្រទេស/ខេត្ត លេខកូតតំបន់/លេខប្រៃសណីយ៍

៩. ប្រទេសដែលអ្នករស់នៅបច្ចុប្បន្ន

១០. លេខទូរស័ព្ទ (ប្រសិនបើមាន)

១១. អាសយដ្ឋានអ៊ីម៉ែល៖ ត្រូវតែជាអាសយដ្ឋានអ៊ីម៉ែលដែលអ្នកប្រើប្រាស់ដោយផ្ទាល់ ហើយនឹងបន្តការប្រើប្រាស់ដោយផ្ទាល់រហូតដល់ខែឧសភានៃឆ្នាំបន្ទាប់។ ប្រសិនបើការចុះឈ្មោះរបស់អ្នកត្រូវបានជ្រើសរើស ហើយអ្នកបន្តដំណើរការនៃការជាប់ឈ្មោះតាមរយៈ *Entrant Status Check* នោះ អ្នកនឹងទទួលបានអ៊ីម៉ែលទំនាក់ទំនងបន្ថែមពីក្រសួងការបរទេសសហរដ្ឋអាមេរិក ជូនដំណឹងអ្នកពីព័ត៌មានលម្អិតអំពីពេលវេលាសម្រាប់សម្ភាសន៍ទិដ្ឋាការអន្តោប្រវេសន៍ប្រសិនបើមាន។ **សំគាល់៖ ក្រសួងការបរទេសនឹងមិនផ្ញើអ៊ីម៉ែលទៅប្រាប់ថាអ្នកត្រូវបានជាប់ឈ្មោះក្នុងកម្មវិធី DV នោះទេ។** សូមមើល សំណួរដែលសួរញឹកញាប់បំផុត សម្រាប់ព័ត៌មានបន្ថែមស្ដីពីដំណើរការចាប់ឈ្មោះ។

១២. កម្រិតសិក្សាដែលអ្នកបានបញ្ចប់ គិតត្រឹមបច្ចុប្បន្ន៖

- បឋមសិក្សា
- វិទ្យាល័យ គ្មានសញ្ញាបត្រ
- វិទ្យាល័យ មានសញ្ញាបត្រ
- សាលាបណ្ដុះបណ្ដាលវិជ្ជាជីវៈ
- មុខវិជ្ជាខ្លះនៅសកលវិទ្យាល័យ
- បរិញ្ញាបត្រពីសកលវិទ្យាល័យ
- មុខវិជ្ជាកម្រិតបញ្ចប់ថ្នាក់ឧត្តមសិក្សាខ្លះ
- អនុបណ្ឌិត
- មុខវិជ្ជាកម្រិតថ្នាក់បណ្ឌិតខ្លះ
- ថ្នាក់បណ្ឌិត



SENSITIVE BUT UNCLASSIFIED

សូមមើល សំណួរដែលសួរញឹកញាប់បំផុតសម្រាប់ព័ត៌មានបន្ថែមស្ដីពីលក្ខខណ្ឌនៃកម្រិតអប់រំ។

**១៣.** ស្ថានភាពអាពាហ៍ពិពាហ៍បច្ចុប្បន្ន៖

- នៅលីវ
- រៀបការហើយ ហើយប្ដី/ប្រពន្ធខ្ញុំ**គ្មាន**សញ្ជាតិអាមេរិក ឬកាន់ហ្គ្រីនកាតនៅសហរដ្ឋអាមេរិក (LPR)ទេ
- រៀបការហើយ ហើយប្ដី/ប្រពន្ធខ្ញុំ**មាន**សញ្ជាតិអាមេរិក ឬជាអ្នកកាន់ហ្គ្រីនកាតនៅសហរដ្ឋអាមេរិក
- លែងលះ
- មេម៉ាយ/ពោះម៉ាយ ឬ
- រស់នៅបែកគ្នាស្របតាមច្បាប់

បញ្ចូលឈ្មោះ ថ្ងៃខែឆ្នាំកំណើត ភេទ ទីក្រុងកំណើត និងប្រទេសកំណើតរបស់ប្ដី/ប្រពន្ធអ្នក និងរូបថតរបស់ប្ដី/ប្រពន្ធអ្នក ឲ្យបានត្រឹមត្រូវទៅតាមលក្ខខណ្ឌរូបថតដូចជារូបថតរបស់អ្នកដែរ។

ការខកខានមិនបានបញ្ចូលឈ្មោះប្ដី/ប្រពន្ធ ឬចុះឈ្មោះបុគ្គលដែលមិនជាប្ដី/ប្រពន្ធរបស់អ្នក អាចធ្វើឲ្យអ្នកបាត់បង់សិទ្ធិជាបេក្ខជនចម្បងសម្រាប់កម្មវិធី DV ហើយឈានដល់ការបដិសេធចំពោះពាក្យសុំទិដ្ឋាការទាំងអស់នៅក្នុងពាក្យសុំរបស់អ្នក នៅពេលសម្ភាសន៍សុំទិដ្ឋាការ។ អ្នកត្រូវតែបញ្ចូលឈ្មោះប្ដី/ប្រពន្ធ ទោះបីជាបច្ចុប្បន្ននេះអ្នករស់នៅបែកគ្នាក៏ដោយ លើកលែងតែអ្នករស់នៅបែកគ្នាដោយស្របច្បាប់។ ការរស់នៅបែកគ្នាដោយស្របច្បាប់គឺជាការព្រមព្រៀងរវាង ប្ដីប្រពន្ធដែលនៅមានចំណងអាពាហ៍ពិពាហ៍ប៉ុន្តែរស់នៅបែកគ្នា ដោយមានដីការសម្រេចពីតុលាការ។ ប្រសិនបើអ្នកនិងប្ដី/ប្រពន្ធរបស់អ្នក បានរស់នៅបែកគ្នាដោយស្របច្បាប់ នោះប្ដី/ប្រពន្ធអ្នកនឹងមិនអាចធ្វើអន្តោប្រវេសន៍ជាមួយ អ្នកតាមរយៈកម្មវិធី DV បានឡើយ។ ការដែលអ្នកបញ្ចូលឈ្មោះប្ដី/ប្រពន្ធដែល បានរស់នៅបែកគ្នាដោយស្របច្បាប់នឹងពុំមានទោសពៃរ៍អ្វីឡើយ។

ប្រសិនអ្នករស់នៅបែកគ្នាដោយគ្មានដីការសម្រេចពីតុលាការ អ្នកចាំបាច់ត្រូវបញ្ចូលឈ្មោះប្ដី/ប្រពន្ធរបស់អ្នក បើទោះបីជាអ្នកមានគម្រោងថានឹងលែងលះគ្នាមុនពេលអ្នកដាក់ពាក្យសុំទិដ្ឋាការ DV ឬប្ដី/ប្រពន្ធរបស់អ្នក មិនមានបំណងធ្វើអន្តោប្រវេសន៍ទៅសហរដ្ឋអាមេរិកក៏ដោយ។

ប្រសិនបើប្ដី/ប្រពន្ធរបស់អ្នកមានសញ្ជាតិអាមេរិក ឬជាអ្នកកាន់ហ្គ្រីនកាត (LPR) សូមកុំបញ្ចូលឈ្មោះគាត់ឡើយ។ ប្ដី/ប្រពន្ធដែលមានសញ្ជាតិអាមេរិក ឬជាអ្នកកាន់ហ្គ្រីនកាត មិនត្រូវការទិដ្ឋាការឡើយ។ ដូច្នេះប្រសិនបើអ្នកជ្រើសរើសយក "married and my spouse IS a U.S. citizen or U.S. LPR" (រៀបការហើយៗប្ដី/ប្រពន្ធខ្ញុំមានសញ្ជាតិអាមេរិក ឬអ្នកកាន់ហ្គ្រីនកាត) នៅក្នុងពាក្យចុះឈ្មោះដាក់ពាក្យកម្មវិធី DV អ្នកនឹងមិនចាំបាច់ផ្ដល់ព័ត៌មានប្ដី/ប្រពន្ធរបស់អ្នកបន្ថែមទៀតឡើយ។ សូមមើល សំណួរដែលសួរញឹកញាប់បំផុត សម្រាប់ព័ត៌មានបន្ថែមអំពីសមាជិកគ្រួសារ។

១៤. ចំនួនកូនក្នុងបន្ទុក៖ បញ្ចូលឈ្មោះ ថ្ងៃខែឆ្នាំកំណើត ភេទ ទីកន្លែងកំណើត និងប្រទេសកំណើត សម្រាប់កូនៗដែលមានអាយុក្រោម ២១ ឆ្នាំ ដែលនៅរស់ ហើយមិនទាន់រៀបការ មិនថាពួកគេកំពុងរស់នៅជាមួយអ្នកឬអត់ ឬមានបំណងទៅជាមួយឬទៅតាមក្រោយឬក៏អត់ក្ដីពេលអ្នកបានទៅរស់នៅសហរដ្ឋអាមេរិក។ សូមបញ្ចូលរូបថតកូននីមួយៗរបស់អ្នក ដោយប្រើប្រាស់លក្ខខណ្ឌរូបភាពដូចរូបថតរបស់អ្នកដែរ។

**សូមកុំភ្លេចបញ្ចូល៖**

- កូនៗបង្កើតដែលនៅរស់របស់អ្នកទាំងអស់
- កូនៗចិញ្ចឹមស្របច្បាប់ដែលនៅរស់របស់អ្នក និង
- កូនចុងដែលនៅរស់ មិនទាន់រៀបការ និងមានអាយុក្រោម ២១ ឆ្នាំរបស់អ្នក នៅថ្ងៃចុះឈ្មោះ ដាក់ពាក្យតាមប្រព័ន្ធអេឡិចត្រូនិករបស់អ្នក បើទោះបីជាអ្នកលែងមានចំណងអាពាហ៍ពិពាហ៍ស្របច្បាប់ជាមួយឪពុក/ម្ដាយរបស់កូនៗទាំងនោះក៏ដោយ ហើយបើទោះបីជាកូនៗទាំងនោះបច្ចុប្បន្នមិនស្នាក់នៅជាមួយអ្នក ហើយ/ឬមិនទៅរស់នៅសហរដ្ឋអាមេរិកជាមួយអ្នកក្ដី។

កូនៗដែលរៀបការហើយ និងកូនៗដែលមានអាយុចាប់ពី ២១ ឆ្នាំឡើងទៅនៅពេលអ្នកចុះឈ្មោះ មិនអាចមានលក្ខណៈសម្បត្តិសមស្របសម្រាប់ដាក់ពាក្យកម្មវិធី DV ឡើយ។ ប៉ុន្តែច្បាប់ស្តីពីការការពារសិទ្ធជាកូន ដែលជួយការពារកូនៗពីការ "ហួសអាយុ" ក្នុងករណីមួយចំនួនដូចជា៖ ប្រសិនបើអ្នកដាក់ពាក្យ DV មុនពេលកូនៗដែលមិនទាន់រៀបការរបស់អ្នកមានអាយុ ២១ ឆ្នាំនោះ ហើយកូនៗនោះមានអាយុ ២១ ឆ្នាំមុនពេលចេញទិដ្ឋាការ ពួកគេអាចត្រូវបានពិចារណាចាត់ចូលថានៅក្រោមអាយុ ២១ ឆ្នាំដដែល ដើម្បីដំណើរការទិដ្ឋាការ។

អ្នកមិនចាំបាច់បញ្ចូលឈ្មោះកូនដែលមានសញ្ជាតិអាមេរិក ឬជាអ្នកកាន់ហ្គ្រីនកាតស្រាប់នៅពេលអ្នកដាក់ពាក្យ DV ឡើយ ដោយសារពួកគេមិនត្រូវការទិដ្ឋាការទៀតឡើយ។ គ្មានទោសពៃរ៍អ្វីឡើយក្នុងករណីដែលអ្នកបញ្ចូល ឬមិនបញ្ចូលឈ្មោះសមាជិកគ្រួសារប្រភេទនេះពេលអ្នកចុះឈ្មោះដាក់ពាក្យ។

ការខកខានមិនបានបញ្ចូលឈ្មោះកូនៗទាំងអស់ដែលមានសិទ្ធិគ្រប់គ្រាន់ ឬបញ្ចូលឈ្មោះអ្នកផ្សេងដែលមិនមែនជាកូនរបស់អ្នក អាចធ្វើឲ្យអ្នកបាត់បង់សិទ្ធិជាបេក្ខជនចម្បងសម្រាប់កម្មវិធី DV និងឈានដល់ការបដិសេធចំពោះពាក្យសុំទិដ្ឋាការទាំងអស់នៅពេលសម្ភាសន៍។ សូមមើលសំណួរដែលសួរញឹកញាប់បំផុត សម្រាប់ព័ត៌មានបន្ថែមស្តីពីសមាជិកគ្រួសារ។

សូមមើល សំណួរដែលសួរញឹកញាប់បំផុត សម្រាប់ព័ត៌មានបន្ថែមអំពីការបំពេញពាក្យចុះឈ្មោះអេឡិចត្រូនិចសម្រាប់កម្មវិធី DV ឆ្នាំ ២០២៦។

## ការជ្រើសរើសបេក្ខជន

យោងទៅតាមការបែងចែកទិដ្ឋាការដែលមានក្នុងតំបន់និងប្រទេសនីមួយៗ ក្រសួងការបរទេសសហរដ្ឋអាមេរិក នឹងជ្រើសរើសបេក្ខជនដោយចៃដន្យតាមរយៈកុំព្យូទ័រពីចំណោមបញ្ជីឈ្មោះដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់។ គ្រប់បេក្ខជន ដែលបានដាក់ពាក្យកម្មវិធី DV ឆ្នាំ ២០២៦ ទាំងអស់ត្រូវចូលទៅ [Entrant Status Check](https://dvprogram.state.gov) ដោយប្រើលេខកូតបញ្ជាក់ពិសេស ដែលខ្លួនរក្សាទុកពីការ ដាក់ពាក្យ DV ឆ្នាំ ២០២៦ តាមប្រព័ន្ធអ៊ីនធើណិត របស់ខ្លួនដើម្បីពិនិត្យមើលថាពាក្យចុះឈ្មោះរបស់ពួកគេត្រូវបានជ្រើសរើសជាប់ក្នុងកម្មវិធី DV ឬទេ។ [Entrant Status Check](https://dvprogram.state.gov) នឹងអាចចូលទៅមើលបានតាមរយៈគេហទំព័រ E-DV [dvprogram.state.gov](https://dvprogram.state.gov) ចាប់ពីថ្ងៃ ទី០៣ ខែឧសភា ឆ្នាំ២០២៥ រហូតដល់ថ្ងៃ ទី៣០ ខែកញ្ញា ឆ្នាំ២០២៦។

ប្រសិនបើពាក្យចុះឈ្មោះរបស់អ្នកត្រូវបានជ្រើសរើស អ្នកនឹងត្រូវមើលទំព័របញ្ជាក់មួយ (confirmation page) ដែលនឹងផ្តល់ការណែនាំបន្ថែម រួមទាំងព័ត៌មានស្តីពីការបង់ថ្លៃទាក់ទងនឹងអន្តោប្រវេសន៍ទៅសហរដ្ឋអាមេរិក។ *Entrant Status Check* គឺជាវិធីតែមួយគត់ដែលក្រសួងការបរទេសសហរដ្ឋអាមេរិកផ្តល់ព័ត៌មានដល់បេក្ខជនជាប់ឈ្មោះ អំពីការជាប់កម្មវិធី DV ឆ្នាំ ២០២៦។ ក្រសួងការបរទេសរបស់សហរដ្ឋអាមេរិកនឹងមិនផ្ញើសំបុត្រ ឬផ្តល់ព័ត៌មានដល់បេក្ខជនជាប់ឈ្មោះតាមអ៊ីម៉ែលឡើយ។ ស្ថានទូត និងស្ថានកុងស៊ុលអាមេរិកនឹងមិនផ្តល់ជាបញ្ជីបេក្ខភាពជាប់ឈ្មោះឡើយ។ បេក្ខជនដែលមិនជាប់ក៏ត្រូវមើលការជូនដំណឹងតាមរយៈ *Entrant Status Check* នេះដូចគ្នា។ សូមចូលទៅមើល *Entrant Status Check* ដោយខ្លួនឯងដោយមិនគួរពឹងពាក់លើអ្នកដទៃឲ្យពិនិត្យនិងផ្តល់ព័ត៌មានដល់អ្នកនោះឡើយ។ ដើម្បីបានទៅរស់សហរដ្ឋអាមេរិក បេក្ខជនជាប់ឈ្មោះក្នុងកម្មវិធី DV ត្រូវតែមានលក្ខណៈគ្រប់គ្រាន់ដើម្បីចូលទៅកាន់ទឹកដីសហរដ្ឋអាមេរិក។ ទម្រង់ DS-260 ពាក្យសុំទិដ្ឋាការអន្តោប្រវេសន៍តាមអ៊ីនធើណិត និងពាក្យសុំចុះឈ្មោះជនបរទេសតាមរយៈប្រព័ន្ធអេឡិចត្រូនិច ព្រមទាំងមន្រ្តីកុងស៊ុលនឹងសួរសំណួរមួយចំនួនដោយផ្ទាល់ទៅបេក្ខជន អំពីលក្ខណៈសម្បត្តិរបស់អ្នកដើម្បីធ្វើអន្តោប្រវេសន៍សហរដ្ឋអាមេរិកស្របតាមច្បាប់អាមេរិក។ សំណួរទាំងនោះបូករួមទាំងប្រធានបទទាក់ទងនឹងឧក្រិដ្ឋកម្ម និងសន្តិសុខជាដើម។

គ្រប់បេក្ខជនជាប់ឈ្មោះរួមទាំងសមាជិកគ្រួសារ ត្រូវតែទទួលទិដ្ឋាការឲ្យបានមុនថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ ២០២៦។ ទោះស្ថិតក្រោមស្ថានភាពណាក៏ដោយក៏ក្រសួងការបរទេសសហរដ្ឋអាមេរិក ឬស្ថាប័ន USCIS មិនអាចចេញទិដ្ឋាការ DV ឬអនុម័តការផ្លាស់ប្តូរណាមួយក្រោយកាលបរិច្ឆេទនេះបានឡើយ ហើយសមាជិកគ្រួសារទាំងនោះក៏មិនអាចទទួលទិដ្ឋាការ DV ដើម្បីទៅតាមក្រោយ

បេក្ខជនចម្បងទៅរស់នៅសហរដ្ឋអាមេរិកនៅក្រោយកាលបរិច្ឆេទនេះបានដែរ។ រដ្ឋាភិបាលសហរដ្ឋអាមេរិក អនុញ្ញាតការចេញទិដ្ឋាការ DV នេះប្រមាណ ៥៥០០០ តែប៉ុណ្ណោះជារៀងរាល់ឆ្នាំ។ ដោយសារតែការផ្តល់ទិដ្ឋាការ DV មានចំនួនកំណត់ បេក្ខជនជាប់ឈ្មោះគួរដាក់ឯកសារផ្សេងៗ និងតាមដានពាក្យសុំរបស់អ្នក អោយបានជាប់លាប់។

សូមមើលសំណួរដែលសួរញឹកញាប់បំផុតសម្រាប់ព័ត៌មានបន្ថែមស្តីពីដំណើរការជ្រើសរើស។

## ការបញ្ចូលរូបថតឌីជីថល (រូបភាព)

អ្នកអាចថតរូបឌីជីថលថ្មីមួយ ឬក៏អាចស្កេនរូបថតថ្មី (ថតក្នុងរយៈពេលប្រាំមួយខែចុងក្រោយ) ដោយកម្មវិធីស្កេនឌីជីថល ឲ្យតែរូបភាពនោះមានលក្ខណៈត្រឹមត្រូវតាមលក្ខខណ្ឌបច្ចេកទេសដូចរៀបរាប់ខាងក្រោម។ រូបថតសម្រាប់ដាក់ពាក្យកម្មវិធី DV ត្រូវតែមានលក្ខណៈដូចនឹងរូបថតសុំទិដ្ឋាការសហរដ្ឋអាមេរិកដែរ។ សម្រាប់គំរូរូបថតដែលអាចទទួលយកបាន សូមចុចទីនេះ។ អ្នកមិនត្រូវបញ្ចូលរូបថតចាស់ ដែលថតលើសពី ៦ខែមុន ឬរូបថតដែលពុំមានលក្ខណៈសមស្របតាមស្តង់ដារដូចមានរៀបរាប់ខាងក្រោមឡើយ។ ការបញ្ចូលរូបថតដដែល ដែលអ្នកធ្លាប់បានបញ្ចូលទៅក្នុងពាក្យចុះឈ្មោះឆ្នាំមុនៗ រូបថតដែលបានកែប្រែ ឬមិនត្រូវទៅតាមលក្ខខណ្ឌតម្រូវខាងក្រោម នឹងធ្វើឲ្យការចុះឈ្មោះរបស់អ្នកត្រូវបានបដិសេធ។

**រូបថតរបស់អ្នកត្រូវមានលក្ខណៈដូចខាងក្រោម៖**

- ពណ៌ធម្មជាតិ
- ច្បាស់
- ទំហំក្បាលបេក្ខជនគឺរវាង ១ អ៊ីញ គុណនឹង ១,៣/៨ អ៊ីញ (២២ ម.ម គុណនឹង ៣៥ ម.ម) ឬ ៥០% គុណនឹង ៦៩% នៃកម្ពស់សរុបរបស់រូបថត រាប់ចាប់ពីចង្កាទៅក្បាល។ សូមមើលលក្ខខណ្ឌបច្ចេកទេសរូបថតសម្រាប់ព័ត៌មានបន្ថែម។
- ថតក្នុងរយៈពេល ៦ ខែចុងក្រោយ ដើម្បីឲ្យស៊ីគ្នាទៅនឹងមុខមាត់របស់អ្នកពេលបច្ចុប្បន្ន
- ផ្ទាំងខាងក្រោយពណ៌.ស
- ថតចំពីមុខពេញ មានទឹកមុខស្មើ និងបើកភ្នែក
- សម្លៀកបំពាក់ធម្មតាដែលអ្នកប្រើប្រចាំថ្ងៃ
- មិនត្រូវប្រើឯកសណ្ឋានឡើយនៅពេលថត លើកលែងតែជាសម្លៀកបំពាក់សាសនាដែលអ្នកប្រើរាល់ថ្ងៃ



SENSITIVE BUT UNCLASSIFIED

- មិនត្រូវពាក់មួក ឬគ្របក្បាលដែលធ្វើឲ្យបាំងសក់ លើកលែងតែពាក់ក្នុងន័យសាសនាជារៀងរាល់ថ្ងៃ ផ្ទៃមុខត្រូវឲ្យឃើញពេញ ហើយការប្រើឆ្នូតក្បាលមិនត្រូវឲ្យបាំងឬចេញជាស្រមោលលើមុខឡើយ
- កាសស្តាប់ ឧបករណ៍គ្មានខ្សែ និងឧបករណ៍ស្រដៀងគ្នានេះផ្សេងៗទៀត មិនត្រូវមានក្នុងរូបថតឡើយ
- មិនត្រូវពាក់វ៉ែនតាឡើយ
- ប្រសិនបើអ្នកប្រើឧបករណ៍ជំនួយការស្តាប់ជាប្រចាំ អ្នកអាចពាក់វាបានពេលថតរូប

សូមមើលគំរូរូបថតដើម្បីមើលរូបថតគំរូដែលអាច និងមិនអាចទទួលយកបាន។ យើងមិនទទួលរូបថតដែលថតចម្លង ឬស្កែនពីប័ណ្ណបើកបរ ឬឯកសារផ្លូវការផ្សេងទៀតឡើយ។ លើសពីនោះ យើងក៏មិនទទួលយករូបថតដែលថតទូទៅធម្មតាៗ រូបថតពីទស្សនាវដ្តី រូបថតចេញពីទូរស័ព្ទ ឬរូបថតមួយជំហរឡើយ។

**អ្នកត្រូវបញ្ចូលរូបថតឌីជីថលនៅពេលអ្នកចុះឈ្មោះ។ រូបថតនោះត្រូវមានលក្ខណៈដូចខាងក្រោម៖**

- ជាទម្រង់ JPEG (.jpg)
- ទំហំស្មើឬតិចជាង ២៤០ គីឡូបៃត៍ (kilobytes)
- មានជ្រុងស្មើគ្នា (កំពស់ត្រូវស្មើទទឹង)
- ទំហំ ៦០០ x ៦០០ ភិចសេល (pixels)

**តើអ្នកចង់ស្កេនរូបថតដែលមានស្រាប់ឬទេ? ក្រៅពីតម្រូវការរូបថតឌីជីថល រូបថតដែលមានស្រាប់ត្រូវតែ៖**

- ទំហំ២ x ២អ៊ីញ (៥១ ម.ម x ៥១ ម.ម)
- ស្កេនក្នុងទំហំ ៣០០ ភិចសេលក្នុងមួយអ៊ីញ (១២ ភិចសេលក្នុងមួយមីលីម៉ែត្រ)

**១. តារាង៖ ថតរូបទារកឬកូនក្មេងអាយុពី ១ ឆ្នាំទៅ ៣ ឆ្នាំ**

នៅពេលអ្នកថតរូបទារក ឬកូនក្មេង មិនត្រូវមានអ្នកផ្សេងនៅក្នុងរូបថតឡើយ ហើយកូនរបស់អ្នកត្រូវសម្លឹងឲ្យចំមកកាម៉េរា និងត្រូវបើកភ្នែក។

| **ព័ត៌មានជំនួយ** | **ការណែនាំ** |
|---|---|
| អ្នកអាច (ទី១) | ដាក់ទារកឲ្យគេងលើក្រណាត់សំពត់ស។ វិធីនេះក្បាលរបស់កូនអ្នកត្រូវបានកល់ និងបង្កើតបានជាផ្ទៃខាងក្រោយពណ៌សផងដែរ។ មិនត្រូវឲ្យមានស្រមោលលើមុខកូនរបស់អ្នកឡើយ ជាពិសេសនៅពេលអ្នកថតពីលើកូន។ |



SENSITIVE BUT UNCLASSIFIED

| | |
|---|---|
| អ្នកអាច (ទី២) | យកក្រណាត់ស មកគ្របកៅអីឡាន ហើយដាក់កូនរបស់អ្នកឲ្យអង្គុយដើម្បីថត។ ធ្វើដូចនេះ ក្បាលរបស់កូនអ្នកមានកំណល់។ |

# សំណួរដែលសួរញឹកញាប់បំផុតពីលក្ខណៈសម្បត្តិកម្មវិធី DV ២០២៦

## លក្ខណៈសម្បត្តិកម្មវិធី DV ២០២៦

### ១. តើពាក្យថា "ប្រជាជនដើម" ឬ "ប្រទេសកំណើតយោង" មានន័យដូចម្តេច?

ប្រជាជនដើមភាគច្រើនសំដៅដល់អ្នកដែលបានកើតនៅក្នុងប្រទេសណាមួយ ដោយមិនគិតអំពីប្រទេសលំនៅបច្ចុប្បន្ន ឬសញ្ជាតិរបស់បុគ្គលនោះឡើយ។ ប្រជាជនដើមក៏អាចមានន័យថាជាអ្នកដែល មានសិទ្ធិយកប្រទេសផ្សេងពីប្រទេសដែលគេបានកើតមកធ្វើជាប្រទេសកំណើតក្រោមមាត្រា ២០២ (ខ) នៃច្បាប់ស្តីពីអន្តោប្រវេសន៍និងសញ្ជាតិ។

ដោយសារមានការកំណត់ចំនួនទិដ្ឋាការទៅលើជនអន្តោប្រវេសន៍ដែលចូលមកពីប្រទេស ឬតំបន់ភូមិសាស្រ្តផ្សេងៗ បុគ្គលម្នាក់ៗត្រូវគេកំណត់ទៅតាមប្រទេសមួយ។ ហើយការកំណត់នោះគឺសំដៅទៅលើប្រទេសដែលអ្នកត្រូវគេរាប់នៅក្នុងការកំណត់ទិដ្ឋាការសម្រាប់ប្រទេសនោះ។ ជាទូទៅ ប្រទេសដែលមានសិទ្ធិដាក់ពាក្យរបស់អ្នកគឺជាប្រទេសដែលអ្នកកើត។ ប៉ុន្តែ អ្នកអាចជ្រើសរើសប្រទេសដែលមានសិទ្ធិចុះឈ្មោះរបស់អ្នក ទៅតាម ប្រទេសកំណើតរបស់ប្តី/ប្រពន្ធរបស់អ្នក ឬប្រទេសកំណើតរបស់ឪពុកឬម្តាយរបស់អ្នក បើសិនអ្នកកើតនៅក្នុងប្រទេសដែលមិនមែនជាប្រទេសកំណើតរបស់ឪពុកឬម្តាយអ្នក ហើយជាប្រទេសដែលឪពុកឬម្តាយរបស់អ្នកពុំមែនជាអ្នករស់នៅស្របច្បាប់នៅពេលអ្នកកើតមកនោះ។ ទាំងនេះជាវិធីតែបីគត់ ដែលអ្នកអាចជ្រើសរើសប្រទេសដើម្បីចុះឈ្មោះរបស់អ្នក។

ការបញ្ចូលប្រទេសដែលមានសិទ្ធិចុះឈ្មោះ ឬប្រទេសយោងមិនត្រឹមត្រូវ (ឧ. ប្រទេសណាដែលអ្នកមិនអាចបញ្ជាក់តាមការអះអាងបាន) អាចធ្វើឲ្យអ្នកមិនអាចដាក់ពាក្យ DV ឆ្នាំ២០២៦បាន។

### ២. តើខ្ញុំនៅតែអាចចុះឈ្មោះបានទេ ប្រសិនបើខ្ញុំមិនបានកើតនៅក្នុងប្រទេសដែលមានសិទ្ធិចុះឈ្មោះផងនោះ?

អ្នកនៅតែអាចមានសិទ្ធិចុះឈ្មោះដោយផ្អែកលើលក្ខខណ្ឌពីរនេះ។ ទីមួយ ប្រសិនប្តី/ប្រពន្ធដែលជាអ្នកទទួលផល តពីអ្នកកើតនៅក្នុងប្រទេសដែលមានសិទ្ធិចុះឈ្មោះ អ្នកអាចយកប្រទេសយោងតាមប្តី/ប្រពន្ធអ្នកបាន។ ដោយសារតែអ្នកចុះឈ្មោះដោយផ្អែកទៅលើប្តី/ប្រពន្ធអ្នក ម្ល៉េះហើយអ្នកអាចទទួលទិដ្ឋាការ



SENSITIVE BUT UNCLASSIFIED

អន្តោប្រវេសន៍បាន

លុះត្រាតែប្តី/ប្រពន្ធរបស់អ្នកមានលក្ខណៈសម្បត្តិសមស្របអាចទទួលបានទិដ្ឋាការអន្តោប្រវេសន៍ប៉ុណ្ណោះ។ អ្នកទាំងពីរត្រូវធ្វើដំណើរជាមួយគ្នាទៅសហរដ្ឋអាមេរិកដោយប្រើប្រាស់ទិដ្ឋាការ DV នេះ។

ដូចគ្នានេះដែរ កូនដែលនៅក្នុងបន្ទុករបស់អ្នកអាច "យកប្រទេសកំណើតយោងតាម" ប្រទេសកំណើតរបស់ឪពុកឬម្តាយបាន។

ទីពីរ អ្នកអាច "យកប្រទេសកំណើតយោងតាម" ប្រទេសកំណើតរបស់ឪពុកឬម្តាយរបស់អ្នកបាន ប្រសិនបើឪពុកនិងម្តាយរបស់អ្នកមិនបានកើត ឬរស់នៅក្នុងប្រទេសកំណើតរបស់អ្នក នៅពេលដែលអ្នកកើតទេនោះ។ ជាទូទៅ បុគ្គលម្នាក់ មិនត្រូវបានចាត់ទុកថាជាប្រជាជននៃប្រទេសមួយទេដរាបណាគេមិនបានកើត ឬចូលសញ្ជាតិដោយស្របច្បាប់ទេនោះ។ ឧទាហរណ៍ពេលនោះគេគ្រាន់តែមកទស្សនកិច្ច (មកដើរលេង) មកសិក្សា ឬមកធ្វើការបណ្តោះអាសន្ននៅក្នុងប្រទេសណាមួយ ពួកគេមិនអាចរាប់ជាប្រជាពលរដ្ឋនៃប្រទេសនោះបានទេ។

ប្រសិនជាអ្នកស្នើយកប្រទេសយោងតាមវិធីណាមួយខាងលើ អ្នកត្រូវផ្តល់ជាការពន្យល់នៅក្នុងពាក្យចុះឈ្មោះ E-DV ក្នុងសំណួរលេខ ៦។

ការបញ្ចូលប្រទេសដែលមានសិទ្ធិចុះឈ្មោះ ឬប្រទេសយោងកំណើតមិនត្រឹមត្រូវ (ឧ. ប្រទេសណាដែលអ្នកមិនអាចបញ្ជាក់តាមការអះអាងបាន) អាចធ្វើឲ្យអ្នកមិនអាចដាក់ពាក្យកម្មវិធី DV បាន។

## ៣. ហេតុអ្វីប្រជាជនដើមនៃប្រទេសមួយចំនួនមិនអាចចូលរួមដាក់ពាក្យកម្មវិធី DV?

គោលបំណងរបស់កម្មវិធី DV គឺផ្តល់ឱកាសអន្តោប្រវេសន៍ដល់ប្រជាជនដែលមិនមែនមកពី "ប្រទេសដែលមានជនអន្តោប្រវេសន៍(ចូលទៅកាន់សហរដ្ឋអាមេរិក)ច្រើន" (high admission countries)។ ច្បាប់សហរដ្ឋអាមេរិកស្រាយពន្យល់ពាក្យ "ប្រទេសដែលមានជនអន្តោប្រវេសន៍ច្រើន" ថាជាប្រទេសដែលមានប្រជាជនសរុប ៥០០០០ នាក់ ដែលទទួលបានទិដ្ឋាការតាមរយៈគ្រួសារនិងការងារ ដែលបានចូលមករស់នៅក្នុងសហរដ្ឋអាមេរិកក្នុងរយៈពេលប្រាំឆ្នាំចុងក្រោយ។ ជារៀងរាល់ឆ្នាំ



SENSITIVE BUT UNCLASSIFIED

ក្រសួងសន្តិសុខមាតុភូមិរបស់សហរដ្ឋអាមេរិក (DHS) ជាអ្នកគណនាលើតួលេខនៃការទទួលចូលនិងការសុំសិទ្ធិរស់នៅរបស់ជនអន្តោប្រវេសន៍ក្នុងប្រភេទទិដ្ឋាការគ្រួសារនិងការងារ ក្នុងរយៈពេលប្រាំឆ្នាំចុងក្រោយ ដើម្បីកំណត់ប្រទេសដែលអាចចាត់ចូលជា "ប្រទេសដែលមានជនអន្តោប្រវេសន៍ច្រើន" ហើយប្រជាជនដើមនៃ ប្រទេសទាំងនេះនឹងពុំអាចចូលរួមដាក់ពាក្យកម្មវិធី DV ប្រចាំឆ្នាំឡើយ។ ដោយសារតែការគណនានេះត្រូវបានធ្វើឡើងជារៀងរាល់ឆ្នាំ ដូច្នេះហើយបានជាបញ្ជីប្រទេសដែលប្រជាជនដើមអាចចូលរួមឬមិនអាចចូលរួមដាក់ពាក្យមានការផ្លាស់ប្តូរពីមួយឆ្នាំទៅមួយឆ្នាំ។

## ៤. តើទិដ្ឋាការ DV ឆ្នាំ២០២៦ ចំនួនប៉ុន្មានដែលនឹងផ្តល់ជូនទៅប្រជាជនដើមនៃតំបន់និងប្រទេសដែលមានសិទ្ធិចុះឈ្មោះនីមួយៗ?

ក្រសួងសន្តិសុខមាតុភូមិរបស់សហរដ្ឋអាមេរិក (DHS) ជាអ្នកកំណត់ចំនួន DV តាមតំបន់នីមួយៗរៀងរាល់ឆ្នាំ ស្របទៅតាមរូបមន្តដែលបានចែងនៅក្នុងមាត្រា ២០៣ (C) នៃច្បាប់ស្តីពីអន្តោប្រវេសន៍និងសញ្ជាតិ (INA)។ ចំនួនទិដ្ឋាការដែលក្រសួងការបរទេសសហរដ្ឋអាមេរិកនឹងចេញជូនដល់ប្រជាជនដើមនៃប្រទេសនីមួយៗ នឹងត្រូវពឹងផ្អែកលើចំនួនកំណត់តាមតំបន់ ចំនួនបេក្ខជនចុះឈ្មោះដែលមកពីប្រទេសនីមួយៗ និងចំនួនបេក្ខជនជាប់ឈ្មោះដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដើម្បីទទួលបានទិដ្ឋាការ។ ទិដ្ឋាការដែលអាចផ្តល់ជូនទៅប្រជាជនដើមនៃប្រទេសណាមួយនឹងមិនលើសពីប្រាំពីរភាគរយនៃទិដ្ឋាការសរុបឡើយ។

## ៥. តើមានលក្ខខណ្ឌអ្វីខ្លះសម្រាប់កម្រិតសិក្សានិងបទពិសោធន៍ការងារ?

ច្បាប់និងបទបញ្ញត្តិអន្តោប្រវេសន៍របស់សហរដ្ឋអាមេរិកតម្រូវថា រាល់បេក្ខជន DV ទាំងអស់ត្រូវតែបញ្ចប់ការសិក្សាយ៉ាងហោចណាស់ត្រឹមកម្រិតវិទ្យាល័យ ឬការសិក្សាមានតម្លៃស្មើ ឬមានបទពិសោធន៍ការងារពីរឆ្នាំក្នុងរយៈពេលប្រាំឆ្នាំចុងក្រោយ ជាមួយប្រភេទការងារដែលតម្រូវឲ្យមានការបណ្តុះបណ្តាលឬបទពិសោធន៍យ៉ាងហោចណាស់ពីរឆ្នាំទើបអាចបំពេញការងារនោះបាន។ "ការសិក្សាកម្រិតវិទ្យាល័យ ឬការសិក្សាមានតម្លៃស្មើ" មានន័យថាបានបញ្ចប់ការសិក្សាដោយជោគជ័យលើមុខវិជ្ជាដែលត្រូវចំណាយពេល ១២ឆ្នាំ នៅថ្នាក់



SENSITIVE BUT UNCLASSIFIED

បឋមសិក្សានិងមធ្យមសិក្សាពីសហរដ្ឋអាមេរិក ឬការបញ្ចប់ការសិក្សាដោយជោគជ័យក្នុងប្រទេសផ្សេងទៀតលើមុខវិជ្ជាផ្លូវការនៅថ្នាក់បឋមសិក្សានិងមធ្យមសិក្សា ដែលមានតម្លៃប្រហាក់ប្រហែលទៅនឹងការសិក្សាថ្នាក់វិទ្យាល័យនៅសហរដ្ឋអាមេរិក។ មានតែការសិក្សាមុខវិជ្ជាផ្លូវការប៉ុណ្ណោះដែលត្រឹមត្រូវតាមលក្ខខណ្ឌនេះបាន។ កម្មវិធីសិក្សាតាមប្រព័ន្ធអ៊ីនធើណិត ឬសញ្ញាប័ត្រដែលមានតម្លៃស្មើ (ដូចជាសញ្ញាប័ត្រតម្លៃស្មើទូទៅ (General Equivalency Diploma G.E.D) មិនអាចទទួលយកបានឡើយ។ ភស្តុតាងនៃឯកសារបញ្ជាក់ការសិក្សា ឬបទពិសោធន៍ការងារត្រូវតែផ្តល់ជូនមន្ត្រីកុងស៊ុលនៅពេលសម្ភាសន៍សុំទិដ្ឋាការ។

ប្រសិនបើអ្នកគ្មានលក្ខណៈសមស្របទៅនឹងលក្ខខណ្ឌនៃការសិក្សា ឬបទពិសោធន៍ការងារទេនោះ ការចុះឈ្មោះរបស់អ្នកនឹងត្រូវបានបដិសេធនៅពេលសម្ភាសន៍សុំទិដ្ឋាការ ហើយអ្នករួមជាមួយនិងគ្រួសាររបស់អ្នកនឹងមិនទទួលបានទិដ្ឋាការឡើយ។

## ៦. តើការងារប្រភេទណាដែលមានលក្ខណៈគ្រប់គ្រាន់សម្រាប់ដាក់ពាក្យការដាក់ពាក្យកម្មវិធី DV ?

ក្រសួងការបរទេសសហរដ្ឋអាមេរិកនឹងប្រើប្រាស់ទិន្នន័យ O*Net Online របស់ក្រសួងការងារសហរដ្ឋអាមេរិក (DOL) ដើម្បីកំណត់លក្ខខណ្ឌសមស្របលើបទពិសោធន៍ការងារ។ ប្រព័ន្ធទិន្នន័យ O*Net Onlineបែងចែកបទពិសោធន៍ការងារជា "ប្រភេទការងារ" ចំនួនប្រាំ។ ស្របពេលដែលមានការងារជាច្រើនត្រូវបានបញ្ចូលទៅក្នុងគេហទំព័ររបស់ DOL មិនមែនគ្រប់ការងារទាំងអស់មានលក្ខណៈគ្រប់គ្រាន់សម្រាប់កម្មវិធី DV នោះទេ។ ដើម្បីចូលរួមដាក់ពាក្យ DV តាមលក្ខខណ្ឌការងារ អ្នកត្រូវតែមានបទពិសោធន៍ពីរឆ្នាំក្នុងការងារដែលបានចាត់ចូលនៅក្នុងប្រភេទ**ការត្រៀមវិជ្ជាជីវៈជាក់លាក់** (Specific Vocational Preparation (SVP) ដែលមានកម្រិត ៧.០ ឬ ខ្ពស់ជាងនេះក្នុងរយៈពេលប្រាំឆ្នាំចុងក្រោយ។

ប្រសិនបើអ្នកគ្មានលក្ខណៈសម្បត្តិសមស្របតាមលក្ខខណ្ឌនៃការសិក្សា ឬបទពិសោធន៍ការងារគ្រប់គ្រាន់ទេនោះ ការចុះឈ្មោះរបស់អ្នកនឹងត្រូវបានបដិសេធនៅពេលសម្ភាសន៍ទិដ្ឋាការ ហើយកូនៗអ្នករួមជាមួយនិងគ្រួសារអ្នកនឹងមិនទទួលបានទិដ្ឋាការឡើយ។

## ៧. តើខ្ញុំអាចស្វែងរកការងារដែលមានលក្ខណៈសមស្របសម្រាប់ដាក់ពាក្យ DV នៅក្នុងប្រព័ន្ធទិន្នន័យ O*Net Online របស់ក្រសួងការងារសហរដ្ឋអាមេរិកបានដោយរបៀបណា?



SENSITIVE BUT UNCLASSIFIED

នៅពេលអ្នកចូលក្នុងគេហទំព័រ **O*Net Online** សូមអនុវត្តតាមជំហានខាងក្រោមដើម្បីកំណត់ថាការងាររបស់អ្នកមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ឬទេ៖

ក. ក្រោមប៊ូតុង "Find Occupation" សូមជ្រើសរើសយកប៊ូតុង "Job Family" ពីតារាងដែលទាញចុះក្រោមបាន

ខ. ស្វែងរកក្នុងតារាង "Job Family" ជ្រើសរើសហើយ ចុច "GO"

គ. ចុចលើលីង (link) សម្រាប់ការងារជាក់លាក់របស់អ្នក

ឃ. ជ្រើសរើសប្រអប់ "Job Zone" ដើម្បីស្វែងរកលេខប្រភេទការងារដែលបានកំណត់ និងកម្រិតកំណត់ការត្រៀមវិជ្ជាជីវៈជាក់លាក់ (SVP)។

ឧទាហរណ៍៖ ជ្រើសរើស "Aerospace Engineers" ។ នៅខាងក្រោម "Summary Report for Aerospace Engineers" ក្រោមផ្នែក "Job Zone" អ្នកនឹងឃើញ "Job Zone 4" កម្រិត SVP ៧.០ ទៅ < ៨.០ ។ ដោយប្រើប្រាស់ឧទាហរណ៍នេះ Aerospace Engineers គឺជាការងារមានលក្ខណៈសម្បត្តិគ្រប់គ្រាន់។

សម្រាប់ព័ត៌មានបន្ថែម សូមមើល កម្មវិធី DV - គេហទំព័រអំពីបញ្ជីការងារ ។

### ៨. តើមានការកំណត់អាយុអប្បបរមានៅក្នុងការចុះឈ្មោះដាក់ពាក្យ E-DV ឬទេ?

គ្មានការកំណត់អាយុក្នុងការចុះឈ្មោះឡើយ ប៉ុន្តែលក្ខខណ្ឌនៃការសិក្សាថ្នាក់វិទ្យាល័យ ឬបទពិសោធន៍ការងារសម្រាប់បេក្ខជនចម្បងនីមួយៗនៅពេលចុះឈ្មោះ នឹងធ្វើឲ្យបេក្ខជនភាគច្រើនដែលមានអាយុក្រោម ១៨ ឆ្នាំមិនអាចចូលរួមដាក់ពាក្យបាន។

## ការបំពេញពាក្យចុះឈ្មោះអេឡិចត្រូនិចសម្រាប់កម្មវិធី DV

### ៩. តើពេលណាខ្ញុំអាចចុះឈ្មោះបាន?

រយៈពេលចុះឈ្មោះដាក់ពាក្យ DV ឆ្នាំ២០២៦ នឹងចាប់ផ្តើមពីថ្ងៃពុធ ទី២ ខែតុលា ឆ្នាំ២០២៤ ម៉ោង១២ថ្ងៃត្រង់ (ម៉ោងនៅសហរដ្ឋអាមេរិក) រហូតដល់ថ្ងៃអង្គារ ទី៥ ខែវិច្ឆិកា ឆ្នាំ២០២៤ ម៉ោង១២ថ្ងៃត្រង់ (ម៉ោងនៅសហរដ្ឋអាមេរិក)។ រៀងរាល់ឆ្នាំ មានបេក្ខជនរាប់លាននាក់បានចុះឈ្មោះ។ ការកំណត់រយៈពេលចុះឈ្មោះតាមកាលបរិច្ឆេទខាងលើនេះ គឺដើម្បីធានាឲ្យបានថាបេក្ខជនទទួលបានការជូនដំណឹងក្នុងរយៈពេលមួយគ្រប់គ្រាន់ ក៏ដូចជាផ្តល់ពេលវេលាឲ្យទាំងបេក្ខជនសុំទិដ្ឋាការ

និងស្ថានទូតនិងស្ថានកុងស៊ុលរបស់យើងមានពេលគ្រប់គ្រាន់សម្រាប់រៀបចំនិងបញ្ចប់ករណីនីមួយៗ ដើម្បីចេញទិដ្ឋាការជូនបេក្ខជន។

យើងលើកទឹកចិត្តអ្នកឲ្យចុះឈ្មោះឲ្យបានរួសរាន់ក្នុងរដូវកាលចុះឈ្មោះ។ ការចុះឈ្មោះដ៏ច្រើនលើសលុបនៅចុងរដូវកាលចុះឈ្មោះ អាចនឹងធ្វើឲ្យប្រព័ន្ធកុំព្យូទ័រដំណើរការយឺត។ យើងនឹងមិនទទួលយកការចុះឈ្មោះក្រោយថ្ងៃអង្គារ ទី៥ ខែវិច្ឆិកា ឆ្នាំ២០២៤ ម៉ោង១២ថ្ងៃត្រង់ (ម៉ោងនៅសហរដ្ឋអាមេរិក)ឡើយ។

**១០. ខ្ញុំនៅសហរដ្ឋអាមេរិក។ តើខ្ញុំអាចចុះឈ្មោះដាក់ពាក្យ DV បានឬទេ?**

បាន។ បេក្ខជនចុះឈ្មោះអាចស្ថិតនៅសហរដ្ឋអាមេរិក ឬក្នុងប្រទេសមួយផ្សេងទៀត ហើយពាក្យចុះឈ្មោះអាចដាក់ពីទីណាក៏បាន។

**១១. ខ្ញុំអាចចុះឈ្មោះបានតែម្តងគត់ក្នុងរដូវកាលចុះឈ្មោះនីមួយៗមែនទេ?**

មែន។

ច្បាប់អនុញ្ញាតឲ្យមានការចុះឈ្មោះតែម្តងប៉ុណ្ណោះសម្រាប់បេក្ខជនម្នាក់ក្នុងរដូវកាលចុះឈ្មោះនីមួយៗ។ ក្រសួងការបរទេសអាមេរិក ប្រើប្រាស់បច្ចេកវិទ្យាទំនើប ដែលអាចដឹងថាមានពាក្យចុះឈ្មោះច្រើនដង។ បេក្ខជនដែលចុះឈ្មោះច្រើនលើសពីម្តង នឹងត្រូវបដិសេធមិនឲ្យចូលរួមដាក់ពាក្យ DV។

**១២. តើប្តី/ប្រពន្ធខ្ញុំ និងខ្ញុំអាចចុះឈ្មោះរៀងៗខ្លួនបានទេ?**

បាន។ ប្តី/ប្រពន្ធ អាចចុះឈ្មោះ ផ្សេងគ្នាបាន ប្រសិនពួកគេមានលក្ខណៈសម្បត្តិដែលសមស្រប។ ប្រសិនបើប្តី/ប្រពន្ធអ្នកត្រូវបានជ្រើសរើស ប្តី/ប្រពន្ធមួយទៀតមានសិទ្ធិដាក់ពាក្យជាបេក្ខជនទទួលផល តាមរយៈប្តី/ប្រពន្ធដែលជាប់ឈ្មោះនោះបាន។

**១៣. តើសមាជិកគ្រួសារណាខ្លះដែលខ្ញុំត្រូវបញ្ចូលទៅក្នុងពាក្យចុះឈ្មោះ DV របស់ខ្ញុំ?**

**ប្តី/ប្រពន្ធ៖** ប្រសិនបើអ្នករៀបការដោយស្របច្បាប់ អ្នកត្រូវបញ្ចូលឈ្មោះប្តី/ប្រពន្ធអ្នក ទោះគេរស់នៅជាមួយអ្នកឬមិននៅជាមួយក្តី មាន បំណងឬគ្មានបំណងធ្វើអន្តោប្រវេសន៍ទៅសហរដ្ឋអាមេរិកជាមួយអ្នកក្តី។ អ្នកត្រូវបញ្ចូលប្តី/ប្រពន្ធអ្នក បើទោះបីជាបច្ចុប្បន្ននេះអ្នកកំពុងរស់នៅបែកគ្នាក៏ដោយ



SENSITIVE BUT UNCLASSIFIED

លើកលែងតែអ្នកបានរស់នៅបែកគ្នាដោយស្របច្បាប់ប៉ុណ្ណោះ។ ការរស់នៅបែកគ្នាដោយស្របច្បាប់ គឺជាការព្រមព្រៀងរវាងប្តីប្រពន្ធដែលនៅមានចំណងអាពាហ៍ពិពាហ៍ប៉ុន្តែរស់នៅបែកគ្នា ដោយមានដីការសម្រេចពីតុលាការ។ ប្រសិនអ្នកនិងប្តី/ប្រពន្ធរបស់អ្នកបានរស់នៅបែកគ្នាដោយស្របច្បាប់ ប្តី/ប្រពន្ធអ្នកនឹងមិនអាចធ្វើអន្តោប្រវេសន៍ជាមួយអ្នកតាមរយៈកម្មវិធី DV ឡើយ។ យើងនឹងមិនពិន័យអ្នកឡើយ ប្រសិនជាអ្នកបញ្ចូលឈ្មោះប្តី/ប្រពន្ធដែលអ្នកបានរស់នៅបែកគ្នាដោយស្របច្បាប់នោះ។ ប្រសិនបើអ្នករស់នៅបែកគ្នាដោយគ្មានដីការសម្រេចពីតុលាការទេ អ្នកត្រូវបញ្ចូលឈ្មោះប្តី/ប្រពន្ធរបស់អ្នក បើទោះបីជាអ្នកមានគម្រោងថានឹងលែងលះគ្នាមុនពេលអ្នកដាក់ពាក្យសុំទិដ្ឋាការប្រភេទ DV ឬប្តី/ប្រពន្ធរបស់អ្នកគ្មានបំណងទៅអាមេរិកជាមួយអ្នកក៏ដោយ។ ប្រសិនបើអ្នកមិនបានចុះឈ្មោះប្តី/ប្រពន្ធរបស់អ្នកដែលមានលក្ខខណ្ឌសមស្រប ឬចុះឈ្មោះបុគ្គលផ្សេងដែលមិនមែនជាប្តី/ប្រពន្ធរបស់អ្នក អ្នកនឹងត្រូវបានបដិសេធទិដ្ឋាការ DV។ ប្រសិនបើអ្នកមិនទាន់បានរៀបការស្របច្បាប់នៅពេលចុះឈ្មោះដាក់ពាក្យនេះ ប៉ុន្តែមានគម្រោងរៀបការស្របច្បាប់នាពេលអនាគតវិញនោះ អ្នកមិនត្រូវចុះឈ្មោះអនាគតប្តី/ប្រពន្ធនោះនៅក្នុងកម្មវិធីនោះឡើយ ព្រោះការធ្វើដូច្នោះនឹងបណ្តាលឲ្យអ្នកត្រូវបានបដិសេធទិដ្ឋាការ។ ប្រសិនបើអ្នកបានលែងលះគ្នាហើយ ឬប្តី/ប្រពន្ធអ្នកបានទទួលមរណភាព អ្នកមិនចាំបាច់បញ្ចូលឈ្មោះពួកគាត់ក្នុងការចុះឈ្មោះរបស់អ្នកឡើយ។

ករណីលើកលែងតែមួយគត់សម្រាប់លក្ខខណ្ឌនេះគឺប្រសិនបើប្តី/ប្រពន្ធរបស់អ្នកមានសញ្ជាតិអាមេរិក ឬជាអ្នកកាន់ហ្គ្រីនកាតរួចទៅហើយ។ ប្រសិនបើប្តី/ប្រពន្ធរបស់អ្នកមានសញ្ជាតិអាមេរិក ឬជាអ្នកកាន់ហ្គ្រីនកាត អ្នកមិនចាំបាច់បញ្ចូលឈ្មោះពួកគេឡើយ។ ប្តី/ប្រពន្ធដែលមានសញ្ជាតិអាមេរិក ឬជាអ្នកកាន់ហ្គ្រីនកាត នឹងមិនត្រូវការទិដ្ឋាការ DV ឡើយ។ ដូចនេះ ប្រសិនបើអ្នកជ្រើសរើសយក "married and my spouse IS a US citizen or U.S LPR (រៀបការហើយ ហើយប្តី/ប្រពន្ធខ្ញុំមានសញ្ជាតិអាមេរិក ឬជាអ្នកកាន់ហ្គ្រីនកាត)" នៅក្នុងពាក្យចុះឈ្មោះរបស់អ្នក អ្នកនឹងមិនអាចបញ្ចូលព័ត៌មានបន្ថែមទៀតអំពីប្តី/ប្រពន្ធរបស់អ្នកទៀតបានឡើយ។

**កូនៗ៖** អ្នកត្រូវបញ្ចូលព័ត៌មានអំពីកូនៗអ្នកទាំងអស់ដែលនៅរស់ មិនទាន់រៀបការ ហើយមានអាយុក្រោម ២១ ឆ្នាំ គិតត្រឹមពេលដែលអ្នកចុះឈ្មោះដាក់ពាក្យ DV



SENSITIVE BUT UNCLASSIFIED

ទោះបីគេជាកូនបង្កើតរបស់អ្នក ជាកូនចុងក្តី (បើទោះបីជាអ្នកបានលែងលះពីឪពុក/ម្តាយរបស់កូនៗនោះក៏ដោយ) កូនៗរបស់ប្តី/ប្រពន្ធអ្នក ឬកូនៗដែលអ្នកបានយកមកចិញ្ចឹមដោយស្របទៅតាមច្បាប់របស់ប្រទេសអ្នក។ អ្នកត្រូវបញ្ចូលព័ត៌មានកូនៗដែលមានអាយុក្រោម ២១ ឆ្នាំ គិតត្រឹមពេលដែលអ្នកចុះឈ្មោះតាមអេឡិចត្រូនិច បើទោះបីជាកូនៗទាំងនោះមិនស្នាក់នៅជាមួយអ្នក ឬអ្នកមិនមានបំណងឲ្យពួកគេទៅរស់នៅតាមទិដ្ឋាការ DV ក៏ដោយ។ អ្នកមិនចាំបាច់បញ្ចូលព័ត៌មានអំពីកូនៗ ដែលមានសញ្ជាតិអាមេរិកឬកាន់ហ្គ្រីនកាតឡើយ ប៉ុន្តែបើអ្នកបញ្ចូលក៏គ្មានបញ្ហាអ្វីដែរ។

ឪពុកម្តាយឬបងប្អូនបង្កើតរបស់បេក្ខជនគ្មានសិទ្ធិទទួលទិដ្ឋាការ DV ក្នុងនាមជាអ្នកទទួលផលឡើយ ហើយអ្នកមិនគួរបញ្ចូលឈ្មោះពួកគេនៅក្នុងពាក្យចុះឈ្មោះរបស់អ្នកដែរ។

ប្រសិនជាអ្នកបញ្ចូលឈ្មោះសមាជិកគ្រួសារអ្នកនៅក្នុងពាក្យចុះឈ្មោះ ពួកគេពុំមែនចាំបាច់ត្រូវតែចុះឈ្មោះសុំទិដ្ឋាការ ឬធ្វើអន្តោប្រវេសន៍ ឬធ្វើដំណើរទៅជាមួយអ្នកឡើយ។ ប៉ុន្តែ ប្រសិនបើអ្នកមិនបានបញ្ចូលឈ្មោះប្តី/ប្រពន្ធ ឬកូនៗ ឬបញ្ចូលឈ្មោះបុគ្គលដែលមិនមែនជាអ្នកត្រូវទទួលផល ពាក្យសុំរបស់អ្នកនឹងត្រូវបានបដិសេធនៅពេលអ្នកសម្ភាសសុំទិដ្ឋាការ ហើយសមាជិកគ្រួសារអ្នកនឹងមិនទទួលបានទិដ្ឋាការឡើយ។ ករណីនេះត្រូវចំពោះតែអ្នកដែលត្រូវជាប្តី/ប្រពន្ធ និងកូនៗនៅពេលចុះឈ្មោះពីដំបូងប៉ុណ្ណោះ ប៉ុន្តែមិនចំពោះប្តី/ប្រពន្ធឬកូនៗដែលអ្នកមានក្រោយពេលចុះឈ្មោះឡើយ។ ប្រសិនបើប្តី/ប្រពន្ធរបស់អ្នកមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ គេក៏អាចចុះឈ្មោះដោយឡែកពីអ្នកបានដែរ ទោះបីជាអ្នកបានបញ្ចូលឈ្មោះគេទៅក្នុងការចុះឈ្មោះរបស់អ្នកក៏ដោយ ឲ្យតែពាក្យចុះឈ្មោះទាំងពីរនេះមានព័ត៌មានលម្អិតអំពីប្តី/ប្រពន្ធនិងកូនៗក្នុងគ្រួសារអ្នក សូមចូលមើល សំណួរលេខ ១២ នៃសំណួរដែលសួរញឹកញាប់បំផុតខាងលើ។

## ១៤. តើខ្ញុំត្រូវតែចុះឈ្មោះនេះដោយខ្លួនឯងផ្ទាល់ ឬអ្នកដទៃអាចចុះឈ្មោះជំនួសខ្ញុំបាន?

អ្នកគួរតែរៀបចំនិងចុះឈ្មោះដោយខ្លួនឯង ប៉ុន្តែអ្នកអាចឲ្យអ្នកដទៃជួយចុះឈ្មោះឲ្យអ្នកបាន។ មិនថាអ្នកចុះឈ្មោះដោយខ្លួនឯង តាមរយៈមេធាវី មិត្តភក្តិ សាច់ញាតិ ឬអ្នកដទៃធ្វើជំនួសអ្នកក្តី ការចុះឈ្មោះរបស់អ្នកត្រូវមានតែមួយប៉ុណ្ណោះ។ ក្នុងនាមជាបេក្ខជនចុះឈ្មោះ អ្នកត្រូ



SENSITIVE BUT UNCLASSIFIED

ធ្វើយ៉ាងណាឲ្យព័ត៌មានទាំងឡាយនៅក្នុងពាក្យចុះឈ្មោះនោះត្រឹមត្រូវនិងពេញលេញ។ ការចុះឈ្មោះទាំងឡាយណាដែលមិនត្រឹមត្រូវឬមិនពេញលេញ នឹងធ្វើឲ្យអ្នកបាត់បង់សិទ្ធិចូលរួមដាក់ពាក្យ DV ។ បេក្ខជន ចុះឈ្មោះត្រូវរក្សាលេខកូតបញ្ជាក់ (confirmation number) ដោយខ្លួនឯង ដើម្បីពួកគេអាចតាមដានលទ្ធផលចុះឈ្មោះរបស់គេ ដោយប្រើប្រាស់ *Entrant Status Check* តាមរយៈគេហទំព័រ dvprogram.state.gov។ បេក្ខជនចុះឈ្មោះគួររក្សាលទ្ធភាពអាចចូលទៅកាន់គណនីអ៊ីម៉ែលដែលគេប្រើប្រាស់នៅក្នុងការចុះឈ្មោះ E-DV ។

**១៥. ខ្ញុំកំពុងដំណើរការសុំទិដ្ឋាការអន្តោប្រវេសន៍ប្រភេទមួយផ្សេងទៀតរួចទៅហើយ។ តើខ្ញុំនៅអាចចុះឈ្មោះ DV បានទេ?**

បាន។

**១៦. តើខ្ញុំអាចទាញយក (download) និងរក្សាទុក (save) ពាក្យចុះឈ្មោះ E-DV ជាទម្រង់កម្មវិធី word ហើយបំពេញវានៅពេលក្រោយបានដែរទេ?**

ទេ អ្នកនឹងមិនអាចរក្សាទុកពាក្យចុះឈ្មោះ E-DV DV ជាទម្រង់កម្មវិធីមួយផ្សេងទៀតដើម្បីបំពេញនៅពេលក្រោយបានឡើយ។ អ្នកត្រូវតែបំពេញព័ត៌មានហើយបញ្ជូនពាក្យនោះពេលកំពុងអនឡាញ។

**១៧. តើខ្ញុំអាចរក្សាទុកពាក្យចុះឈ្មោះនៅលើអ៊ីនធើណិតហើយបំពេញវានៅពេលក្រោយបានដែរទេ?**

ទេ។ ទម្រង់ពាក្យចុះឈ្មោះ E-DV ត្រូវបានកំណត់ឲ្យបំពេញនិងបញ្ចូលក្នុងពេលតែម្តងប៉ុណ្ណោះ។ អ្នកមានរយៈពេល ៦០នាទី រាប់ចាប់ពីពេលអ្នកទាញយកពាក្យមកបំពេញនិងបញ្ចូលពាក្យចុះឈ្មោះរបស់អ្នកតាមរយៈគេហទំព័រ E-DV។ ប្រសិនបើអ្នកបំពេញហួសពី ៦០នាទី ហើយមិនទាន់បានបញ្ចូលពាក្យចុះឈ្មោះទៅក្នុងប្រព័ន្ធអេឡិចត្រូនិចទេនោះ ប្រព័ន្ធកុំព្យូទ័រនឹងលុបចោលព័ត៌មានដែលបានបញ្ចូលទាំងអស់។ ប្រព័ន្ធកុំព្យូទ័រនឹងលុបចោលរាល់ព័ត៌មានទាំងឡាយណាដែលបានបំពេញមិនពេញលេញ ដើម្បីកុំឲ្យប្រព័ន្ធច្រលំហើយចាត់ទុកថាការចុះឈ្មោះស្ទួនគ្នានឹងពាក្យដែលបំពេញពេញលេញនៅពេលក្រោយទៀត។ សូមអាន



SENSITIVE BUT UNCLASSIFIED

សេចក្តីណែនាំពីការដាក់ពាក្យ DV ឲ្យបានច្បាស់លាស់ មុននឹងអ្នកចាប់ផ្តើមបំពេញពាក្យលើប្រព័ន្ធអ៊ីនធើណិត ដើម្បីដឹងឲ្យច្បាស់ថាអ្នកត្រូវការព័ត៌មានអ្វីខ្លះ។

## ១៨. ខ្ញុំគ្មានឧបករណ៍ស្កេនទេ។ តើខ្ញុំអាចផ្ញើរូបថតទៅនរណាម្នាក់ឲ្យគេស្កេន រក្សាទុក ហើយផ្ញើតាមអ៊ីម៉ែលមកឲ្យខ្ញុំវិញ ដើម្បីខ្ញុំយកវាទៅប្រើសម្រាប់ចុះឈ្មោះបានទេ?

បាន! ឲ្យតែរូបថតនោះមានលក្ខណៈសមស្របទៅតាមលក្ខខណ្ឌដូចមានចែងក្នុងសេចក្តីណែនាំ ហើយត្រូវបានបញ្ចូលតាមប្រព័ន្ធអេឡិចត្រូនិចស្របពេលពេលជាមួយការបំពេញពាក្យចុះឈ្មោះ E-DV។ អ្នកត្រូវត្រៀមរូបថតដែលបានស្កេនឲ្យហើយ នៅពេលអ្នកកំពុងចុះឈ្មោះតាមអ៊ីនធើណិត។ រូបថតនិងពាក្យចុះឈ្មោះនេះមិនអាចបញ្ចូលនៅពេលផ្សេងគ្នាបានឡើយ។ ពាក្យចុះឈ្មោះទាំងមូល (រូបថតនិងពាក្យ) អាចដាក់តាមប្រព័ន្ធអេឡិចត្រូនិចពីសហរដ្ឋអាមេរិក ឬពីប្រទេសផ្សេងបាន។

## ១៩. បើសិនប្រព័ន្ធ E-DV បដិសេធមិនព្រមទទួលពាក្យចុះឈ្មោះរបស់ខ្ញុំ តើខ្ញុំអាចបញ្ជូនពាក្យចុះឈ្មោះម្តងទៀតបានទេ?

បាន! ប្រសិនការចុះឈ្មោះរបស់អ្នកត្រូវបានបំពេញត្រឹមថ្ងៃអង្គារ ទី៥ ខែវិច្ឆិកា ឆ្នាំ២០២៤ ម៉ោង១២ថ្ងៃត្រង់ (ម៉ោងនៅសហរដ្ឋអាមេរិក)។ អ្នកនឹងមិនរងពិន័យអ្វីឡើយចំពោះការចុះឈ្មោះពីរដង ប្រសិនបើប្រព័ន្ធ E-DV បានបដិសេធការចុះឈ្មោះលើកទីមួយរបស់អ្នកហើយនោះ។ ដោយសារយើងមិនអាចដឹងពីភាពរអាក់រអួលរបស់ប្រព័ន្ធអ៊ីនធើណិតជាមុន អ្នកអាចនឹងមិនទទួលព័ត៌មានអំពីការបដិសេធភ្លាមៗឡើយ។ អ្នកអាចសាកល្បងចុះឈ្មោះច្រើនដងតាមដែលចាំបាច់ រហូតដល់ពាក្យដែលពេញលេញជោគជ័យ ហើយអ្នកទទួលបានព័ត៌មានបញ្ជាក់ថាពាក្យសុំរបស់អ្នកបានបញ្ជូនជោគជ័យហើយ។ ប៉ុន្តែប្រសិនបើអ្នកទទួលបានការបញ្ជាក់ហើយ មានន័យថាពាក្យចុះឈ្មោះរបស់អ្នកពេញលេញហើយ អ្នក<u>មិន</u>ត្រូវបញ្ជូនពាក្យបន្ថែមទៀតឡើយ។

## ២០. តើខ្ញុំអាចទទួលការបញ្ជាក់ជាសារអេឡិចត្រូនិចពេលណា បន្ទាប់ពីខ្ញុំចុះឈ្មោះហើយ?

អ្នកគួរតែទទួលបានការជូនព័ត៌មានបញ្ជាក់ភ្លាមៗ រួមទាំងលេខកូតបញ្ជាក់ ដែលអ្នកត្រូវតែកត់និងរក្សាទុកផងដែរ។ ប៉ុន្តែ ភាពរអាក់រអួលរបស់ប្រព័ន្ធអ៊ីនធើណិតអាចធ្វើឲ្យមានការពន្យារពេល។ អ្នកអាចចុចប៊ូតុង "Submit" ច្រើនដងតាមដែលចាំបាច់ រហូតដល់ការដាក់ពាក្យបានបញ្ជូនសព្វគ្រប់ ហើយអ្នកទទួលបាន



SENSITIVE BUT UNCLASSIFIED

ការបញ្ជាក់ពីប្រព័ន្ធថាបានទទួលពាក្យអ្នកហើយ។ ប៉ុន្តែ នៅពេលអ្នកទទួលបានការបញ្ជាក់ហើយ អ្នកមិនត្រូវបញ្ជូនពាក្យម្តងទៀតឡើយ។

**២១. ខ្ញុំបានចុចប៊ូតុង "Submit" ហើយ ប៉ុន្តែមិនបានទទួលលេខកូតបញ្ជាក់ (Confirmation Number) ទេ។ ប្រសិនខ្ញុំបញ្ចូលពាក្យចុះឈ្មោះមួយទៀត តើខ្ញុំនឹងត្រូវគេបដិសេធឬទេ?**

ប្រសិនអ្នកមិនបានទទួលលេខកូតបញ្ជាក់ទេ បានសេចក្តីថាការចុះឈ្មោះរបស់អ្នកមិនត្រូវបានបញ្ចូលក្នុងប្រព័ន្ធកុំព្យូទ័រឡើយ។ អ្នកត្រូវតែបញ្ចូលពាក្យចុះឈ្មោះមួយទៀត។ វានឹងមិនត្រូវបានចាត់ចូលថាស្ទួនគ្នាឡើយ។ នៅពេលដែលអ្នកទទួលបានលេខកូតបញ្ជាក់ហើយ អ្នកមិនត្រូវចុះឈ្មោះម្តងទៀតឡើយ។

## ការជ្រើសរើស

**២២. តើធ្វើដូចម្តេចទើបអាចដឹងថាខ្ញុំជាបេក្ខជនជាប់ឈ្មោះ?**

អ្នកត្រូវប្រើលេខកូតបញ្ជាក់ (confirmation number) ដើម្បីចូលទៅកាន់ទំព័រឆែកលទ្ធផលបេក្ខជន (Entrant Status Check) ដែលមាននៅក្នុងគេហទំព័រ E-DV តាមរយៈ dvprogram.state.gov ចាប់ពីថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០២៥ ដល់ថ្ងៃ ទី៣០ ខែកញ្ញា ឆ្នាំ២០២៦។ Entrant Status Check គឺជាវិធីតែមួយគត់ដែលក្រសួងការបរទេសសហរដ្ឋអាមេរិកនឹងផ្តល់ដំណឹងដល់អ្នក ប្រសិនអ្នកជាប់ឈ្មោះ ក៏ដូចជាផ្តល់ការណែនាំបន្ថែមអំពីដំណើរការសុំទិដ្ឋាការរបស់អ្នក និងផ្តល់ព័ត៌មានអំពីកាលបរិច្ឆេទនិងពេលវេលាសម្ភាសន៍ទិដ្ឋាការអន្តោប្រវេសន៍ដល់អ្នក។ ដើម្បីធានាថាទិដ្ឋាការដែលមានទាំងអស់ត្រូវបានប្រើប្រាស់ ក្រសួងការបរទេសអាមេរិកអាចនឹងប្រើប្រាស់ Entrant Status Check ដើម្បីជ្រើសរើសបេក្ខជនបន្ថែមទៀតបន្ទាប់ពីថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០២៥ តទៅ។ សូមរក្សាលេខកូតបញ្ជាក់រហូតដល់ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២៦ ក្នុងករណីមានព័ត៌មានបន្ថែម។ គេហទំព័រក្រសួងការបរទេសអាមេរិកតែមួយគត់ ដែលទទួលការចុះឈ្មោះតាមអ៊ីនធើណិតក្នុងកម្មវិធី DV និងការឆែកលទ្ធផលបេក្ខជន (Entrant Status Check) គឺ dvprogram.state.gov។

ក្រសួងការបរទេសនឹង**មិន**ទាក់ទងអ្នកដើម្បីប្រាប់ថាអ្នកជាប់ឈ្មោះនោះឡើយ (សូមមើល សំណួរសួរញឹកញាប់បំផុតលេខ ២៥)។



SENSITIVE BUT UNCLASSIFIED

## ២៣. តើធ្វើដូចម្តេចទើបខ្ញុំដឹងថាខ្ញុំមិនមែនជាបេក្ខជនជាប់ឈ្មោះ? តើគេនឹងជូនដំណឹងមកខ្ញុំឬយ៉ាងណា?

ក្រសួងការបរទេសសហរដ្ឋអាមេរិកនឹងមិនផ្តល់ដំណឹងដល់អ្នកដោយផ្ទាល់ឡើយ ប្រសិនបើពាក្យចុះឈ្មោះរបស់អ្នកមិនបានជាប់ឈ្មោះ។ អ្នកអាចឆែកលទ្ធផលពាក្យចុះឈ្មោះ DV ឆ្នាំ ២០២៦បាន តាមរយៈ Entrant Status Check លើគេហទំព័រ E-DV ចាប់ពីថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០២៥ ដល់ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២៦។ សូមរក្សាលេខកូតបញ្ជាក់របស់អ្នករហូតដល់យ៉ាងហោចណាស់ត្រឹមថ្ងៃទី ៣០ ខែកញ្ញា ឆ្នាំ២០២៦។ (ព័ត៌មានពីលទ្ធផលសម្រាប់កម្មវិធី DV ឆ្នាំមុន គឺDV ឆ្នាំ២០២៥ អាចចូលទៅមើលបានតាមប្រព័ន្ធអ៊ិនធើណិតរហូតដល់ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២៥)។

## ២៤. តើខ្ញុំត្រូវធ្វើដូចម្តេចប្រសិនបើខ្ញុំបាត់លេខកូតបញ្ជាក់ (confirmation number) របស់ខ្ញុំ?

អ្នកត្រូវមានលេខកូតបញ្ជាក់ដើម្បីចូលទៅ Entrant Status Check ។ ឥឡូវនេះមានកម្មវិធីដែលអាចប្រើប្រាស់បាននៅក្នុង Entrant Status Check នៅលើគេហទំព័ររបស់ E-DV ដែលនឹងអនុញ្ញាតឲ្យអ្នកទាញយកលេខកូតបញ្ជាក់របស់អ្នកមកវិញតាមរយៈអាសយដ្ឋានអ៊ីម៉ែលដែលអ្នកបានចុះឈ្មោះ ដោយបញ្ចូលនូវព័ត៌មានផ្ទាល់ខ្លួនមួយចំនួនដើម្បីបញ្ជាក់ពីអត្តសញ្ញាណរបស់អ្នក។

ស្ថានទូតអាមេរិកនិងស្ថានកុងស៊ុល ព្រមទាំងមជ្ឈមណ្ឌលស្ថានកុងស៊ុលខេនថាក់គី (Kentucky Consular Center) មិនអាចឆែកលទ្ធផលជូនអ្នក ឬផ្តល់ជាលេខកូតបញ្ជាក់របស់អ្នកដោយផ្ទាល់បានទេ (ក្រៅតែពីតាមរយៈកម្មវិធីទាញយកដែលមាននៅក្នុង Entrant Status Check ប៉ុណ្ណោះ)។ ក្រសួងការបរទេសសហរដ្ឋអាមេរិក**មិន**អាចផ្តល់ជាបញ្ជីអ្នកជាប់ឈ្មោះ ដើម្បីបន្តដំណើរការទិដ្ឋាការបានឡើយ។

## ២៥. តើខ្ញុំនឹងទទួលបានព័ត៌មានពីក្រសួងការបរទេសសហរដ្ឋអាមេរិកតាមរយៈអ៊ីម៉ែលឬប្រៃសណីយ៍?

ក្រសួងការបរទេសសហរដ្ឋអាមេរិកនឹងមិនផ្ញើលិខិតជូនដំណឹងអ្វីដល់អ្នកឡើយ។ រដ្ឋាភិបាលសហរដ្ឋអាមេរិកនឹងមិនផ្ញើជាអ៊ីម៉ែល ដើម្បីផ្តល់ជូនដំណឹងដល់បុគ្គលណាម្នាក់ថាគេបានជាប់ឈ្មោះឡើយ ហើយក៏គ្មានគម្រោងថានឹងប្រើប្រាស់អ៊ីម៉ែលសម្រាប់គោលបំណងនេះក្នុងកម្មវិធី DV ប្រចាំឆ្នាំ២០២៦ នេះដែរ។ ប្រសិនបើអ្នកជាបេក្ខជនជាប់ឆ្នោត អ្នកនឹងទទួលបានការទាក់ទងគ្នាតាមអ៊ីម៉ែលអំពីការសម្ភាសសុំទិដ្ឋាការរបស់អ្នក**បន្ទាប់**ពីអ្នកបានឆ្លើយ

តបទៅនឹងសេចក្តីជូនដំណឹងអំពីសេចក្តីណែនាំនៅលើ Entrant Status Check (ESC) ប៉ុណ្ណោះ ។ អ៊ីម៉ែលទាំងនេះនឹងមិនផ្តល់ព័ត៌មានអំពីកាលបរិច្ឆេទនិងពេលវេលាសម្ភាសន៍ឡើយ។ អ៊ីម៉ែលទាំងនេះគ្រាន់តែប្រាប់អ្នកឲ្យចូលទៅគេហទំព័រ Entrant Status Check សម្រាប់ព័ត៌មានលម្អិតប៉ុណ្ណោះ។ ក្រសួងការបរទេសសហរដ្ឋអាមេរិកអាចនឹងផ្ញើជាអ៊ីម៉ែលរំលឹកដល់បេក្ខជន DV ឲ្យចូលទៅមើល ESC ដើម្បីឆែកមើលលទ្ធផលរបស់ខ្លួន។ ប៉ុន្តែអ៊ីម៉ែលទាំងនោះនឹងមិនបញ្ជាក់ថាបេក្ខជនបានជាប់ឬមិនបានជាប់ឈ្មោះឡើយ។

មានតែគេហទំព័រដែលបញ្ចប់ដោយ ".gov" ប៉ុណ្ណោះ ដែលជាគេហទំព័រផ្លូវការរបស់រដ្ឋាភិបាលសហរដ្ឋអាមេរិក។ គេហទំព័រផ្សេងទៀតជាច្រើន (ឧ. ដែលបញ្ចប់ដោយ ".com" ".org" ឬ ".net") ផ្តល់ជាព័ត៌មានស្តីអំពីសេវាកម្មពាក់ព័ន្ធនឹងអន្តោប្រវេសន៍ និងទិដ្ឋាការដែរ។ ក្រសួងការបរទេសសហរដ្ឋអាមេរិកមិនបានយល់ព្រម គាំទ្រ ឬឧបត្ថម្ភជាព័ត៌មានឬឯកសារណាមួយដែលមាននៅលើគេហទំព័រទាំងនោះឡើយ។

**សារព្រមាន៖** អ្នកអាចនឹងទទួលអ៊ីម៉ែលពីគេហទំព័រមួយចំនួន ដែលបញ្ឆោតអ្នកឲ្យផ្ញើជាសាច់ប្រាក់ ឬផ្តល់ជាព័ត៌មានផ្ទាល់ខ្លួនជាដើម។ អ្នកអាចត្រូវគេទាមទារបង់ប្រាក់លើពាក្យចុះឈ្មោះ និងព័ត៌មានអំពីនីតិវិធីអន្តោប្រវេសន៍ជាដើម ដែលតាមពិតទៅព័ត៌មានទាំងនេះ មានផ្តល់ជូនដោយឥតគិតថ្លៃនៅលើគេហទំព័រក្រសួងការបរទេសសហរដ្ឋអាមេរិក travel.state.gov ឬតាមរយៈគេហទំព័រស្ថានទូត ឬស្ថានកុងស៊ុលសហរដ្ឋអាមេរិក។ បន្ថែមពីនេះ ស្ថាបនឬគេហទំព័រទាំងនេះអាចនឹងព្យាយាមលួចលុយរបស់អ្នក ដោយ គិតថ្លៃទៅលើសេវាកម្មផ្សេងៗពាក់ព័ន្ធនឹងកម្មវិធី DV ជាដើម។ ប្រសិនបើអ្នកផ្ញើ ប្រាក់ទៅស្ថាប័នឬគេហទំព័រដែលពុំមែនជារបស់រដ្ឋាភិបាលអាមេរិកទាំងនេះណាមួយហើយ នោះពួកគេអាចនឹងឈប់ទាក់ទងជាមួយអ្នកភ្លាម។ ហើយអ្នកក៏មិនត្រូវផ្ញើព័ត៌មានផ្ទាល់ខ្លួន ទៅឲ្យគេហទំព័រទាំងនេះដែរ ដោយសារវាអាចជាការលួចឬក្លែងបន្លំអត្តសញ្ញាណរបស់អ្នកជាដើម។

អ៊ីម៉ែលបោកបញ្ឆោតទាំងនេះអាចផ្ញើមកពីជនដែលបន្លំថាមានទំនាក់ទំនងជាមួយនឹងមជ្ឈមណ្ឌលស្ថានកុងស៊ុលខេនថាក់គី (Kentucky Consular Center) របស់ក្រសួងការបរទេសសហរដ្ឋអាមេរិក។ **សូមចងចាំថា រដ្ឋាភិបាលអាមេរិកនឹងមិនផ្ញើអ៊ីម៉ែលដើម្បីផ្តល់ដំណឹងដល់បេក្ខជនថាពួកគេជាប់ឈ្មោះទេ ហើយក៏គ្មានគម្រោងថានឹងប្រើប្រាស់អ៊ីម៉ែលសម្រាប់កម្មវិធី DV ប្រចាំឆ្នាំ២០២៦ នេះដែរ។ ក្រសួងការបរទេសនឹងមិនតម្រូវឲ្យអ្នកផ្ញើទឹកប្រាក់តាមប្រៃសណីយ៍ ឬតាមសេវាកម្មវេសស្ទើន យូនៀន**

**(Western Union) ដែរ បើទោះបីជានៅពេលដាក់ពាក្យសុំសិទ្ធិរស់នៅពីស្ថាប័ន USCIS តម្រូវឲ្យមានការបង់ថ្លៃប្រៃសណីយ៍ក្តី។** សម្រាប់ព័ត៌មានបន្ថែម លើការដាក់ពាក្យសុំសិទ្ធិរស់នៅពីស្ថាប័នUSCIS សូមចូលទៅគេហទំព័រ នេះ។

## ២៦. តើបេក្ខភាពប៉ុន្មាននាក់នឹងត្រូវបានជ្រើសរើសសម្រាប់កម្មវិធី DV ឆ្នាំ ២០២៦?

យោងតាមច្បាប់ ទិដ្ឋាការDVអាចមាន ចំនួនរហូតដល់ ៥៥០០០ ច្បាប់ជារៀងរាល់ឆ្នាំសារពើពន្ធ។ ការប៉ាន់ស្មានចំនួនទិដ្ឋាការ កម្មវិធី DV ប្រចាំឆ្នាំ២០២៦នេះ នឹងប្រកាសនៅក្នុងព្រឹត្តិបត្រទិដ្ឋាការ នៅដើមឆ្នាំសារពើពន្ធនៃកម្មវិធី DV ២០២៦។

ជារៀងរាល់ឆ្នាំ ក្រសួងការបរទេសសហរដ្ឋអាមេរិកនឹងជ្រើសរើសបេក្ខភាពលើសពី ៥៥០០០នាក់ ដើម្បីបំពេញបេក្ខភាពខ្លះដែលនឹងមិនទទួលបានទិដ្ឋាការក៏ដូចជាបេក្ខភាពខ្លះទៀតដែលនឹងបោះបង់ករណីរបស់គេ។ ប៉ុន្តែ ចំណុចនេះក៏មានន័យថា អាចនឹងមិន មានចំនួនទិដ្ឋាការគ្រប់គ្រាន់សម្រាប់អ្នកដែលបានជាប់ឈ្មោះទាំងអស់ ផងដែរ។ យ៉ាងណាមិញ ក្រសួងការប្រទេសប្រើវិធីនេះក៏ដើម្បីប្រើឲ្យអស់ទិដ្ឋាការដែលមានចំនួនប្រមាណ៥៥០០០ច្បាប់នេះ។

អ្នកអាចឆែក Entrant Status Check តាមគេហទំព័ររបស់កម្មវិធី E-DV ដើម្បីពិនិត្យមើលថាអ្នកបានជាប់ឈ្មោះដើម្បីបន្តដំណើរការសុំទិដ្ឋាការទៅមុខទៀតឬអត់ ក៏ដូចជាដើម្បីបន្តតាមដានករណីរបស់អ្នកផងដែរ។ ការសម្ភាសន៍សម្រាប់កម្មវិធី DV ឆ្នាំ២០២៦ នឹងចាប់ផ្តើមនៅខែតុលា ឆ្នាំ២០២៥ សម្រាប់អ្នកជាប់ឈ្មោះដែលបានបំពេញ ឯកសារក៏ដូចជាព័ត៌មានទាំងឡាយមុនការសម្ភាសន៍ ដូចដែលបានណែនាំនៅក្នុងសេចក្តីជូនដំណឹង។ បេក្ខជនជាប់ឈ្មោះដែលបានផ្តល់ព័ត៌មានទៅតាមការតម្រូវអស់ហើយ នឹងទទួលបានព័ត៌មានស្តីពីការសម្ភាសន៍របស់ពួកគេតាមរយៈ Entrant Status Check នៅលើគេហទំព័ររបស់កម្មវិធី E-DV ពីបួនទៅប្រាំមួយសប្តាហ៍ មុនកិច្ចសម្ភាសន៍របស់គេជាមួយនឹងមន្ត្រីកុងស៊ុល។

ជារៀងរាល់ខែ ទិដ្ឋាការនឹងត្រូវចេញជូនដល់បេក្ខជនដែលមានលក្ខណៈគ្រប់គ្រាន់ ដើម្បីទទួលបានទិដ្ឋាការក្នុងខែនោះ ឲ្យតែនៅមានទិដ្ឋាការ។ នៅពេលដែលទិដ្ឋាការ DV ដែលអាចមានប្រមាណជា ៥៥០០០ ច្បាប់ ត្រូវបានចេញជូនអស់ហើយនោះ កម្មវិធីក៏នឹងបញ្ចប់ដែរ។ ចំនួនទិដ្ឋាការអាចត្រូវបានចេញជូនអស់មុនខែកញ្ញា ២០២៦។ បេក្ខជនជាប់ឈ្មោះដែលមានបំណងចង់ទទួលបានទិដ្ឋាការ ត្រូវតែត្រៀមខ្លួនឲ្យបានសមស្របសម្រាប់



SENSITIVE BUT UNCLASSIFIED

ករណីរបស់ពួកគេ។

**បេក្ខជនដែលជាប់ឈ្មោះដោយការជ្រើសរើសដោយចៃដន្យមិនមែនមានន័យថាគេនឹងទទួលបានទិដ្ឋាការនោះទេ។**

**ការជាប់ឈ្មោះនេះគ្រាន់តែមានន័យថាអ្នកមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដើម្បីចុះឈ្មោះសុំទិដ្ឋាការ DV ប៉ុណ្ណោះ។**

**ប្រសិនបើលេខរៀងរបស់អ្នកមានលក្ខណៈសម្បត្តិគ្រប់គ្រាន់សម្រាប់ដំណើរការចេញទិដ្ឋាការចុងក្រោយ អ្នកអាចមានឱកាសខ្ពស់ក្នុងការទទួលបានទិដ្ឋាការ DV។ មានតែចំនួនទិដ្ឋាការអតិបរមា ៥៥០០០ ច្បាប់ប៉ុណ្ណោះ ដែលនឹងចេញជូនបេក្ខជនដែលមានលក្ខណៈសម្បត្តិដូចនេះ។**

## ២៧. តើបេក្ខជនចុះឈ្មោះបានជោគជ័យនឹងត្រូវបានជ្រើសរើសយ៉ាងដូចម្តេច?

ការជូនដំណឹងនៃការជ្រើសរើសជាផ្លូវការនឹងធ្វើឡើងតាមរយៈ Entrant Status Check ដែលអាចចូលមើលបាន**ចាប់ពីថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០២៥ រហូតដល់ថ្ងៃទី ៣០ ខែកញ្ញា ឆ្នាំ២០២៦ នៅលើគេហទំព័រ E-DV** dvprogram.state.gov**។**

**ក្រសួងការបរទេសសហរដ្ឋអាមេរិកមិនផ្តល់ដំណឹងឬលិខិតតាមរយៈអ៊ីម៉ែល ឬប្រៃសណីយ៍ទៅបេក្ខជនឡើយ។ រាល់អ៊ីម៉ែលឬសំបុត្រតាមប្រៃសណីយ៍ទាំងឡាយណាដែលបញ្ជាក់ថាអ្នកត្រូវបានជ្រើសរើសដើម្បីទទួលទិដ្ឋាការ DV ដែលគ្មានប្រភពមកពីក្រសួងការបរទេសសហរដ្ឋអាមេរិក គឺមិនត្រឹមត្រូវស្របច្បាប់ឡើយ។ រាល់ទំនាក់ទំនងតាមអ៊ីម៉ែលដែលអ្នកទទួលបានពីក្រសួងការបរទេសសហរដ្ឋអាមេរិក នឹងប្រាប់អ្នកឲ្យទៅមើលក្នុង Entrant Status Check សម្រាប់ព័ត៌មានបន្ថែមអំពីពាក្យសុំទិដ្ឋាការរបស់អ្នក។ ក្រសួងការបរទេសសហរដ្ឋអាមេរិកនឹងមិនស្នើឲ្យអ្នកផ្ញើទឹកប្រាក់តាមប្រៃសណីយ៍ ឬតាមសេវាកម្មផ្សេងទៀតដូចជាវេសស្ទើន យូនៀន (Western Union) នោះឡើយ លើកលែងតែ អ្នកសុំសិទ្ធិរស់នៅទៅកាន់ស្ថាប័នUSCIS។** សម្រាប់ព័ត៌មានបន្ថែម លើការដាក់ពាក្យសុំសិទ្ធិរស់នៅពីស្ថាបនUSCIS សូមចូលទៅគេហទំព័រ នេះ។

គ្រប់ពាក្យចុះឈ្មោះទាំងអស់ដែលទទួលបានពីតំបន់នីមួយៗត្រូវបានកំណត់ដោយលេខដោយឡែកពីគ្នា។ នៅរដូវកាលបញ្ចប់នៃការចុះឈ្មោះ ប្រព័ន្ធកុំព្យូទ័រនឹងជ្រើសរើសពាក្យចុះឈ្មោះដោយចៃដន្យពីបណ្តាពាក្យចុះឈ្មោះទាំងអស់ដែលបានទទួលពីតំបន់នីមួយៗ។ ក្នុងតំបន់នីមួយៗ ពាក្យចុះឈ្មោះទីមួយដែលបានជ្រើសរើសដោយ

ចៃដន្យ នឹងក្លាយជាករណីដំបូងដែលចុះក្នុងបញ្ជី។ ពាក្យចុះឈ្មោះទីពីរដែលបានជ្រើសរើសដោយចៃដន្យ នឹងក្លាយជាករណីទីពីរ។ល។ រាល់ពាក្យចុះឈ្មោះទាំងអស់ដែលទទួលបានពីតំបន់នីមួយៗក្នុងរដូវកាលចុះឈ្មោះនឹងមានឱកាសស្មើៗគ្នា។ នៅពេលដែលពាក្យចុះឈ្មោះត្រូវបានជ្រើសរើស បេក្ខជននឹងទទួលបានព័ត៌មានអំពីការជ្រើសរើសតាមរយៈ Entrant Status Check ចាប់ពីថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០២៥ នៅក្នុងគេហទំព័រ E-DV dvprogram.state.gov។ ប្រសិនបើអ្នកត្រូវបានជ្រើសរើស ហើយអ្នកឆ្លើយតបទៅនឹងសេចក្តីណែនាំដែលបានផ្តល់ជូនតាមអ៊ីនធើណិតនៅលើ Entrant Status Check មជ្ឈមណ្ឌលស្ថានកុងស៊ុលខេនថាក់គីនៃក្រសួងការបរទេសសហរដ្ឋអាមេរិក (KCC) នឹងចាប់ផ្តើមដំណើរការសុំណុំរឿងរបស់អ្នករហូតដល់បេក្ខជនជាប់ឆ្នោតត្រូវបានណែនាំដើម្បីចូលសម្ភាសទិដ្ឋាការនៅស្ថានទូត ឬស្ថានកុងស៊ុលសហរដ្ឋអាមេរិក ឬរហូតដល់បេក្ខជនដែលនៅសហរដ្ឋអាមេរិកហើយកំពុងដាក់ពាក្យសុំសិទ្ធិរស់នៅបានដាក់ពាក្យទៅកាន់ការិយាល័យ USCIS។

## ២៨. ពេលនេះខ្ញុំស្ថិតនៅសហរដ្ឋអាមេរិក។ ប្រសិនបើជាប់ឈ្មោះ តើខ្ញុំអាចសុំសិទ្ធិរស់នៅទៅកាន់ស្ថាប័នUSCIS បានទេ?

បាន! ក្នុងករណីដែលអ្នកមានលក្ខណៈសម្បត្តិសមស្របក្នុងការសុំសិទ្ធិរស់នៅ ក្រោមបទបញ្ញត្តិនៃមាត្រា ២៤៥ នៃច្បាប់ស្តីពីអន្តោប្រវេសន៍និងសញ្ជាតិ (INA) អ្នកអាចដាក់ពាក្យទៅកាន់ស្ថាប័ន USCIS ដើម្បីសុំសិទ្ធិជាអ្នករស់នៅអចិន្ត្រៃយ៍បាន។ អ្នកត្រូវប្រាកដថាស្ថាប័ន USCIS អាចដំណើរការករណីរបស់អ្នកបានដូចជា ការចុះឈ្មោះប្តី/ប្រពន្ធ ឬសម្រាប់កូនៗក្រោមអាយុ ២១ឆ្នាំរបស់អ្នកដែលនៅប្រទេសផ្សេងឲ្យបាន មុនថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២៦ ដោយសារពេលកាលបរិច្ឆេទនេះមកដល់ សិទ្ធិរបស់អ្នកនៅក្នុងកម្មវិធី DV ឆ្នាំ២០២៦ នឹងផុតសុពលភាព។ ក្រសួងការបរទេសសហរដ្ឋអាមេរិកនឹងមិនអនុម័តលើទិដ្ឋាការ ឬធ្វើការផ្លាស់ប្តូរសិទ្ធិរស់នៅណាមួយសម្រាប់កម្មវិធី DV ឆ្នាំ២០២៦ ឡើយ បន្ទាប់ពីពាក់កណ្តាលយប់ EDT នៅថ្ងៃទី ៣០ ខែកញ្ញា ឆ្នាំ២០២៦។

## ២៩. ប្រសិនបើខ្ញុំជាប់ឈ្មោះ តើខ្ញុំមាន សិទ្ធិយូរប៉ុណ្ណាដើម្បីចុះឈ្មោះសុំទិដ្ឋាការ DV?



SENSITIVE BUT UNCLASSIFIED

ប្រសិនបើអ្នកជាប់ឈ្មោះក្នុងកម្មវិធី DV ២០២៦ អ្នកមានសិទ្ធិចុះឈ្មោះសុំទិដ្ឋាការតែត្រឹមក្នុងអំឡុងឆ្នាំសារពើពន្ធ ២០២៦ របស់រដ្ឋាភិបាលសហរដ្ឋអាមេរិកប៉ុណ្ណោះ ពោលគឺចាប់ផ្ដើមពីថ្ងៃទី១ ខែតុលា ឆ្នាំ២០២៥ រហូតដល់ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២៦។ បេក្ខជនដែលជាប់ឈ្មោះត្រូវចុះឈ្មោះសុំទិដ្ឋាការឲ្យបានឆាប់បំផុតនៅពេលដែលវេណករណីរបស់ពួកគេមានសុពលភាព។ ដូចដែលបានកត់សម្គាល់ខាងលើ នៅពេលដែលទិដ្ឋាការ DV ដែលអាចមានប្រមាណជា ៥៥០០០ ច្បាប់ ត្រូវបានចេញជូនអស់ហើយនោះ កម្មវិធីក៏នឹងបញ្ចប់ដែរ។

**គ្រប់បេក្ខជនជាប់ឈ្មោះដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ត្រូវតែទទួលទិដ្ឋាការ ឬសុំសិទ្ធិរស់នៅឲ្យបានមុន បញ្ចប់ឆ្នាំសារពើពន្ធ ដោយគ្មានករណីលើកលែង។**
សូមបញ្ជាក់ថាគ្មានការបន្តអត្ថប្រយោជន៍ DV ទៅឆ្នាំបន្ទាប់សម្រាប់បេក្ខជនជាប់ឈ្មោះដែលមិនបានទទួលទិដ្ឋាការត្រឹមថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២៦ (នៅពេលបញ្ចប់ឆ្នាំសារពើពន្ធ) នោះឡើយ។ បន្ថែមពីនេះ ប្ដី/ប្រពន្ធនិងកូនៗដែលទទួលបានសិទ្ធិតាមរយៈបេក្ខជនជាប់ឈ្មោះ DV ឆ្នាំ២០២៦ អាចទទួលបានទិដ្ឋាការនៅក្នុងប្រភេទ DV ចាប់ពីថ្ងៃទី១ ខែតុលា ឆ្នាំ២០២៥ ដល់ ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២៦ ប៉ុណ្ណោះ។ បេក្ខភាពដែលបានចុះឈ្មោះពីក្រៅប្រទេសនឹងទទួលបានសេចក្តីជូនដំណឹងអំពីការសម្ភាសពីក្រសួងការបរទេសសហរដ្ឋអាមេរិក តាមរយៈ Entrant Status Check នៅលើគេហទំព័រ E-DV ពីបួនទៅប្រាំមួយសប្ដាហ៍មុនពេលកំណត់ឲ្យសម្ភាសន៍។

### ៣០. ប្រសិនបេក្ខជនជាប់ឈ្មោះស្លាប់ តើករណីនេះនឹងទៅជាយ៉ាងណា?

ប្រសិនបើបេក្ខភាពជាប់ឈ្មោះស្លាប់មុនធ្វើដំណើរទៅសហរដ្ឋអាមេរិក ឬសុំសិទ្ធិរស់នៅ ករណី DV នោះនឹងត្រូវបិទដោយស្វ័យប្រវត្តិ។ ប្ដី/ប្រពន្ធឬកូនៗដែលទទួលសិទ្ធិតាមរយៈបេក្ខជនជាប់ឈ្មោះចម្បងដែលស្លាប់នោះ ក៏នឹងអស់សិទ្ធិទទួលទិដ្ឋាការពីកម្មវិធី DV ដែរ។ រាល់ទិដ្ឋាការណាដែលបានចេញជូនពួកគេនឹងត្រូវបានលុបវិញ។

## ការបង់ថ្លៃកម្មវិធី DV

### ៣១. តើការចុះឈ្មោះដាក់ពាក្យ DVត្រូវបង់ថ្លៃអស់ប៉ុន្មាន?



SENSITIVE BUT UNCLASSIFIED

**ការចុះឈ្មោះតាមប្រព័ន្ធអេឡិចត្រូនិចពុំតម្រូវឲ្យមានការបង់ថ្លៃអ្វីឡើយ។** ប៉ុន្តែ ប្រសិនបើអ្នកជាប់ឈ្មោះ ហើយដាក់ពាក្យសុំទិដ្ឋាការ DV អ្នកត្រូវបង់ថ្លៃពាក្យសុំទិដ្ឋាការនៅពេលចុះឈ្មោះ សុំទិដ្ឋាការនិងសម្ភាសន៍ដោយផ្ទាល់ទៅបេឡាករប្រចាំកុងស៊ុល នៅឯស្ថានទូត ឬស្ថានកុងស៊ុលសហរដ្ឋអាមេរិក។ ប្រសិនបើអ្នកជាបេក្ខជនជាប់ឈ្មោះស្ថិតនៅសហរដ្ឋអាមេរិកស្រាប់ ហើយអ្នកដាក់ពាក្យសុំសិទ្ធិរស់នៅទៅកាន់ស្ថាប័ន USCIS អ្នកនឹងត្រូវបង់ថ្លៃនានាដែល តម្រូវដោយផ្ទាល់ទៅស្ថាប័ន USCIS។ ប្រសិនបើអ្នកជាប់ឈ្មោះ អ្នកនឹងទទួលបានព័ត៌មានលម្អិតអំពីការ បង់ថ្លៃដែលតម្រូវសម្រាប់ពាក្យសុំទិដ្ឋាការ DV និងអន្តោប្រវេសន៍រួមជាមួយនិងការណែនាំ ដែលបានផ្តល់ ជូនតាមរយៈគេហទំព័រ E-DV គឺ dvprogram.state.gov។

## ៣២. តើខ្ញុំត្រូវបង់ថ្លៃទិដ្ឋាការអន្តោប្រវេសន៍ DV ដូចម្តេចហើយនៅទីណា ប្រសិនបើខ្ញុំជាប់ឈ្មោះ?

ប្រសិនបើអ្នកបានជាប់ឈ្មោះហើយ អ្នកនឹងទទួលបានការណែនាំសម្រាប់ដំណើរការពាក្យសុំទិដ្ឋាការ DV តាមរយៈ Entrant Status Check នៅគេហទំព័រ dvprogram.state.gov។ អ្នកនឹងត្រូវបង់ថ្លៃពាក្យសុំទិដ្ឋាការ DV និងអន្តោប្រវេសន៍ទាំងអស់ដោយផ្ទាល់នៅស្ថានទូត ឬស្ថានកុងស៊ុលសហរដ្ឋអាមេរិកនៅពេលដាក់ពាក្យសុំទិដ្ឋាការ និងពេលសម្ភាសសុំទិដ្ឋាការ។ បេឡាករកុងស៊ុលនឹងផ្តល់បង្កាន់ដៃបង់ប្រាក់របស់រដ្ឋាភិបាលសហរដ្ឋអាមេរិកជូនអ្នកវិញភ្លាមៗ។ អ្នកមិនត្រូវផ្ញើប្រាក់សម្រាប់ថ្លៃទិដ្ឋាការ DV ទៅនរណាម្នាក់តាមរយៈប្រៃសណីយ៍ សេវាផ្ទេរប្រាក់វេសស្ទើនយូនៀន ឬសេវាកម្មដឹកជញ្ជូនផ្សេងទៀតឡើយ ប្រសិនបើអ្នកកំពុងដាក់ពាក្យសុំទិដ្ឋាការអន្តោប្រវេសន៍នៅស្ថានទូត ឬស្ថានកុងស៊ុលសហរដ្ឋអាមេរិក។

ប្រសិនបើអ្នកជាប់ឈ្មោះហើយអ្នកកំពុងស្ថិតនៅសហរដ្ឋអាមេរិក ហើយមានគម្រោងចុះឈ្មោះសុំសិទ្ធិ រស់នៅជាមួយស្ថាប័ន USCIS អ្នកអាចចូលទៅមើលនៅលើទំព័រព័ត៌មានណែនាំតាមរយៈ Entrant Status Check នៅគេហទំព័រ dvprogram.state.gov ដែលមានព័ត៌មានណែនាំអំពីវិធីបញ្ជូន ប្រាក់បង់ថ្លៃដាក់ពាក្យសុំសិទ្ធិរស់នៅពីស្ថាប័នUSCIS ទៅធនាគារនៅសហរដ្ឋអាមេរិក។

## ៣៣. ប្រសិនបើខ្ញុំចុះឈ្មោះដាក់ពាក្យ DV ប៉ុន្តែគ្មានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដើម្បីទទួលបានទិដ្ឋាការ តើខ្ញុំនឹងទទួលប្រាក់ដែលខ្ញុំបានបង់សម្រាប់ពាក្យសុំទិដ្ឋាការមកវិញឬទេ?

ទេ! ការបង់ថ្លៃពាក្យសុំទិដ្ឋាការនឹងមិនសងទៅបេក្ខជនវិញឡើយ។ អ្នកត្រូវមានគ្រប់លក្ខណៈសម្បត្តិទាំងអស់សម្រាប់ទិដ្ឋាការ

ដូចបានលម្អិតនៅក្នុងសេចក្តីណែនាំទាំងនេះ។ ប្រសិនបើមន្ត្រីកុងស៊ុលកំណត់ថាអ្នកមិនមានលក្ខណៈសមស្របដើម្បីទទួលទិដ្ឋាការ ឬអ្នកមិនមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ក្រោមច្បាប់របស់សហរដ្ឋអាមេរិកទេនោះ មន្ត្រីកុងស៊ុលមិនអាចចេញទិដ្ឋាការជូនអ្នកបានឡើយ ហើយអ្នកនឹងមិនអាចបានថ្លៃដែលបានបង់ហើយទៅវិញដែរ។

## លក្ខណៈសម្បត្តិដែលមិនសមស្រប

**៣៤. ក្នុងនាមជាបេក្ខជនជាប់ឈ្មោះ DV តើខ្ញុំអាចទទួលបានការលើកលែងសម្រាប់ករណីមិនមានលក្ខណៈសម្បត្តិសមស្របណាមួយសម្រាប់ទិដ្ឋាការបានឬទេ? តើពាក្យសុំការលើកលែងរបស់ខ្ញុំទទួលបានដំណើរការពិសេសណាមួយឬទេ?**

បេក្ខជនជាប់ឈ្មោះក្នុងកម្មវិធី DV នឹងត្រូវវាយតម្លៃទៅតាមលក្ខណៈសម្បត្តិដែលមិនអាចទទួលបានទិដ្ឋាការទាំងអស់ដូចដែលមានចែងនៅក្នុងច្បាប់ស្តីពីអន្តោប្រវេសន៍និងសញ្ជាតិ (INA) ។ គ្មានការផ្តល់ជូនពិសេសណាមួយស្តីពីការលើកលែងចំពោះលក្ខណៈសម្បត្តិផ្សេងៗដែលមិនអាចទទួលបានទិដ្ឋាការក្រៅពីការលើកលែងទាំងឡាយដែលបានបញ្ជាក់នៅក្នុងច្បាប់ INA ហើយក៏គ្មានការអនុញ្ញាតឲ្យមានការស្នើសុំការលើកលែងនោះដែរ។ ការផ្តល់ជូនការលើកលែងទូទៅមួយចំនួនសម្រាប់អ្នកដែលមានសាច់ញាតិបង្កើតដែលមានសញ្ជាតិអាមេរិក ឬកាន់ប្រ៊ីនកាត អាចផ្តល់ជូនបេក្ខជនជាប់ឈ្មោះ DV បានក្នុងករណីមួយចំនួន ប៉ុន្តែពេលវេលាមានកំណត់នៅក្នុងកម្មវិធី DV អាចបង្កលក្ខណៈលំបាកសម្រាប់បេក្ខជនក្នុងការទទួលបានអត្ថប្រយោជន៍ពីការផ្តល់ជូនទាំងនោះ។

## ការក្លែងបន្លំនិងការបោកបញ្ឆោតទាក់ទងនឹងកម្មវិធី DV

**៣៥. តើខ្ញុំអាចរាយការណ៍ពីការក្លែងបន្លំតាមអ៊ីនធើណិត ឬអ៊ីម៉ែលដែលផ្ញើមកដោយមិនបានស្នើសុំដោយវិធីណា?**

សូមចូលទៅកាន់គេហទំព័រ econsumer.gov ដែលគ្រប់គ្រងដោយគណៈកម្មការពាណិជ្ជកម្មសហព័ន្ធសហការជាមួយនឹងភ្នាក់ងារការពារអ្នកប្រើប្រាស់មកពីបណ្តាប្រទេសចំនួន៣៦។ អ្នកក៏អាចរាយការណ៍ពីអំពើក្លែងបន្លំទៅ មជ្ឈមណ្ឌលបណ្តឹងឧក្រិដ្ឋកម្មអ៊ីនធើណិត



SENSITIVE BUT UNCLASSIFIED

របស់ប៉ូលីសស៊ើបអង្កេតសហព័ន្ធ (FBI) ផងដែរ។
ដើម្បីចុះឈ្មោះបណ្តឹងអំពីអ៊ីម៉ែលដែលផ្ញើមកដោយមិនបានស្នើសុំ
អ្នកអាចប្រើប្រាស់កម្មវិធីចុះឈ្មោះបណ្តឹង "Telemarking and Spam"
ឬចូលទៅអ៊ីម៉ែលពាណិជ្ជកម្មក្លែងបន្លំ នៃក្រសួងយុត្តិធម៌ សម្រាប់ព័ត៌មានបន្ថែម។

## ស្ថិតិទិដ្ឋការ DV

### ៣៦. តើមានទិដ្ឋាការចំនួនប៉ុន្មាននឹងត្រូវចេញជូនបេក្ខជនសម្រាប់ DV ឆ្នាំ២០២៦?

យោងតាមច្បាប់ មានចំនួនទិដ្ឋាការអតិបរមា ៥៥០០០ ច្បាប់នឹងត្រូវផ្តល់ជូនទៅបេក្ខជនដែលមាន លក្ខណៈសម្បត្តិសមស្រប ជារៀងរាល់ឆ្នាំ។

## សំណួរផ្សេងៗ

### ៣៧. ប្រសិនបើខ្ញុំទទួលបានទិដ្ឋាការតាមរយៈកម្មវិធី DV តើរដ្ឋាភិបាលសហរដ្ឋអាមេរិកនឹងចេញថ្លៃហោះហើររបស់ខ្ញុំទៅសហរដ្ឋអាមេរិក ជួយខ្ញុំរកកន្លែងស្នាក់នៅនិងការងារ និង/ឬផ្តល់ការថែទាំសុខភាព ឬឧបត្ថម្ភធនធានណាមួយរហូតដល់ខ្ញុំអាចរស់នៅបានដោយខ្លួនឯងដែរឬទេ?

ទេ។ រដ្ឋាភិបាលសហរដ្ឋអាមេរិកនឹងមិនផ្តល់សេវាកម្មណាមួយខាងលើនេះឡើយ
ប្រសិនបើអ្នកទទួលបានទិដ្ឋាការតាមរយៈកម្មវិធី DV។
ប្រសិនបើអ្នកត្រូវបានជ្រើសរើសដើម្បីដាក់ពាក្យសុំទិដ្ឋាការ DV មុននឹងអ្នកអាចទទួលបានទិដ្ឋាការ
អ្នកត្រូវបង្ហាញថាអ្នកនឹងមិនក្លាយជាជនដែលពឹងផ្អែកលើរដ្ឋាភិបាលសហរដ្ឋអាមេរិកឡើយ។
ប្រសិនបើអ្នកជាប់ឈ្មោះ ហើយដាក់ពាក្យសុំទិដ្ឋាការ DV
អ្នកត្រូវយល់ដឹងពីសេចក្តីណែនាំជាសាធារណៈរបស់ក្រសួងការបរទេសអំពីកត្តាផ្សេងៗដែលចាត់ទុកជាការពឹងផ្អែកទៅលើរដ្ឋាភិបាលអាមេរិក
ហើយឲ្យបានដឹងថាភស្តុតាងអ្វីខ្លះដែលអ្នកអាចផ្តល់ដើម្បីបញ្ជាក់ថាអ្នកនឹងមិនក្លាយជាបុគ្គលដែលត្រូវពឹងផ្អែកលើរដ្ឋាភិបាលអាមរិក។



SENSITIVE BUT UNCLASSIFIED

## បញ្ជីប្រទេស/តំបន់តាមភូមិសាស្ត្រដែលប្រជាជនដើមមានសិទ្ធិដាក់ពាក្យ DV ឆ្នាំ ២០២៦

បញ្ជីខាងក្រោមនេះបង្ហាញអំពីប្រទេសដែលប្រជាជនដើមមានសិទ្ធិនៅក្នុងកម្មវិធី DV ឆ្នាំ ២០២៦ ដែលបែងចែកជាក្រុមតាមតំបន់ភូមិសាស្ត្រ។ តំបន់រណបនៅក្រៅប្រទេសត្រូវបានបញ្ចូលនៅក្នុងតំបន់របស់ប្រទេសចម្បង។ ស្ថាប័ន DHS បានកំណត់ប្រទេសដែលប្រជាជនដើមមិនមានសិទ្ធិក្នុងកម្មវិធី DV ឆ្នាំ ២០២៦ យោងទៅតាមរូបមន្តក្នុងមាត្រា ២០៣ (គ) នៃច្បាប់ INA ។ ប្រទេសដែលមានប្រជាជនដើមគ្មានសិទ្ធិនៅក្នុងកម្មវិធី DV (ដោយសារប្រទេសទាំងនេះជាប្រភពចម្បងនៃអន្តោប្រវេសន៍ប្រភេទគ្រួសារនិងការងារ ឬ "ប្រទេសដែលមានអន្តោប្រវេសន៍ច្រើន") ត្រូវបានកំណត់នៅខាងក្រោមបញ្ជីតាមតំបន់នេះ។

### តំបន់អាហ្វ្រិក

- អាល់ហ្សេរីយ៉ា
- អង់ហ្គោឡា
- បេណាំង
- បុតស្វាណា
- បួគីណាហ្វាសូ
- ប៊ូរុនឌី
- កាមេរូន
- កាប់វែរ
- សាធារណរដ្ឋអាហ្វ្រិកកណ្ដាល
- ឆាដ
- កូម័រ
- កុងហ្គោ
- សាធារណរដ្ឋកូតឌីវ័រ
- ជីប៊ូទី
- អេហ្ស៊ីប*
- ហ្គីណេអេក្វាទ័រ
- អេរីត្រេ
- អេសវ៉ាទីនី
- អេត្យូពី
- ហ្គាបុង
- ហ្គំប៊ី
- ហ្គាណា
- ហ្គីណេ
- ហ្គីណេប៊ីស្សូ
- កេនយ៉ា
- ឡេសូតូ
- លីបេរីយ៉ា
- លីប៊ី
- ម៉ាដាហ្គាស្ការ
- ម៉ាឡាវី
- ម៉ាលី
- ម៉ូរីតានី
- ម៉ូរីស
- ម៉ារ៉ុក
- ម៉ូសំប៊ិក
- ណាមីប៊ី
- នីហ្សេ
- រវ៉ាន់ដា
- សៅតូម៉េនិងប្រាំងស៊ីប
- សេណេហ្គាល់
- សីស្ហែល
- សៀរ៉ាឡេអូន
- សូម៉ាលី
- អាហ្វ្រិកខាងត្បូង
- ស៊ូដង់ខាងត្បូង
- ស៊ូដង់
- តង់សានី
- តូហ្គោ
- ទុយនេស៊ី
- អ៊ូហ្គង់ដា
- សំប៊ី
- ស៊ីមបាវ៉េ

***សំគាល់៖*** ក្នុងទ្វីបអាហ្វ្រិក ប្រជាជនដើមមកពីនីហ្សេរីយ៉ា**ពុំមាន**សិទ្ធិដាក់ពាក្យកម្មវិធី DV នៅឆ្នាំនេះឡើយ។

**<u>តំបន់អាស៊ី</u>**

- អាហ្វហ្គានីស្ថាន
- បារ៉ែន
- ប៊ូតង់
- ព្រុយណេ
- ភូមា
- កម្ពុជា
- ឥណ្ឌូណេស៊ី
- អ៊ីរ៉ង់
- អ៊ីរ៉ាក់
- អ៊ីស្រាអែល *
- ជប៉ុន***
- ហ្ស៊កដានី *
- កូវ៉ែត
- ឡាវ
- លីបង់
- ម៉ាឡេស៊ី
- ម៉ាល់ឌីវ
- ម៉ុងហ្គោលី
- នេប៉ាល់
- កូរ៉េខាងជើង
- អូម៉ង់
- កាតា
- អារ៉ាប៊ីសាអូឌីត
- សឹង្ហបុរី
- ស្រីលង្កា
- ស៊ីរី *
- តៃវ៉ាន់ **
- ថៃ
- ទីម័រ
- អារ៉ាប់រួម
- យេម៉ែន

* បុគ្គលដែលបានកើតនៅក្នុងតំបន់ដែលបានគ្រប់គ្រង មុនខែមិថុនា ឆ្នាំ ១៩៦៧ ដោយអ៊ីស្រាអែល ហ្ស៊កដានី ស៊ីរី និងអេហ្ស៊ីប ត្រូវយកប្រទេសកំណើតទៅតាមលំដាប់លំដោយពី អ៊ីស្រាអែល ហ្ស៊កដានី ស៊ីរី និងអេហ្ស៊ីប ។ បុគ្គលដែលកើតនៅតំបន់ហ្គាហ្សាស្រ្ទីប (Gaza Strip) ត្រូវយកប្រទេសកំណើតទៅតាមប្រទេសអេហ្ស៊ីប។ បុគ្គលដែលកើតនៅក្នុង តំបន់វេសទ៍បេងក៏ (West Bank) ត្រូវយកប្រទេសកំណើតទៅតាមប្រទេសហ្ស៊កដានី។ បុគ្គលដែលកើតនៅក្នុង តំបន់ហ្គោលេនហៃត៍ (Golan Heights) ត្រូវយកប្រទេសកំណើតទៅតាមប្រទេសស៊ីរី។

** ម៉ាកាវ S.A.R (តំបន់អឺរ៉ុបយកតាមព័រទុយហ្កាល់) និងតៃវ៉ាន់ (តំបន់អាស៊ី) **មានសិទ្ធិ** ហើយត្រូវបានបញ្ចូលនៅក្នុងបញ្ជីនេះ។ សម្រាប់តែគោលបំណងដាក់ពាក្យកម្មវិធី DV ប៉ុណ្ណោះ បុគ្គលដែលកើតនៅម៉ាកាវ S.A.R ទាញយកសិទ្ធិពីព័រទុយហ្កាល់។

***បុគ្គលដែលកើតនៅបណ្តាប្រជុំកោះហាបូមី ស៊ីកូតាន គូណាស៊ីរី និងអេតូរូហ្វូននឹងយកទៅតាមប្រទេសជប៉ុន។ បុគ្គលដែលកើតនៅខេត្តសាខាលីនខាងត្បូងនឹងយកប្រទេសកំណើតទៅតាមប្រទេសរុស្ស៊ី។

## ប្រជាជនដើមនៃបណ្តាតំបន់ប្រទេសអាស៊ីទាំងនេះមិនមានសិទ្ធិនៅក្នុងកម្មវិធី DV ឆ្នាំនេះឡើយ៖

- បង់ក្លាដែស
- ចិន (រួមទាំងហុងកុងផង)
- ឥណ្ឌា
- ប៉ាគីស្ថាន
- កូរ៉េខាងត្បូង
- ហ្វីលីពីន
- វៀតណាម

## <u>តំបន់អឺរ៉ុប</u>

- អាល់បានី
- អង់ដូរ៉ា
- អាមេនី
- អូទ្រីស
- អាស៊ែបៃហ្សង់
- បេឡារុស
- បែលហ្ស៊ិក
- បូស្នីនិងហើហ្សេហ្គោវីណា
- ប៊ុលហ្គារី
- ក្រូអាស៊ី
- ស៊ីប
- សាធារណរដ្ឋឆែក
- ដាណឺម៉ាក (រួមទាំងផ្នែកនិងតំបន់រណបនៅបរទេស)
- អេស្តូនី
- ហ្វាំងឡង់
- បារាំង (រួមទាំងផ្នែកនិងតំបន់រណបនៅបរទេស)
- ហ្សកហ្ស៊ី
- អាល្លឺម៉ង់
- ចក្រភពអង់គ្លេស (រួមទាំងផ្នែកនិងតំបន់រណបនៅបរទេស)
- ក្រិក
- ហុងគ្រី
- អ៊ីស្លង់
- អៀរឡង់
- អ៊ីតាលី
- កាហ្សាក់ស្ថាន
- កូសូវ៉ូ
- កៀហ្ស៊ីគីស្ថាន
- ឡេតូនី
- លិចតិនស្តាញ
- លីទុយអានី
- លុចសំបួ
- ម៉ាកាវ តំបន់រដ្ឋបាលពិសេស **
- ម៉ាសេដ្វានខាងជើង
- ម៉ាល់ត៍
- ម៉ុលដូវ៉ា
- ម៉ូណាកូ
- ម៉ុងតេណេហ្គ្រោ
- ហូឡង់ (រួមទាំងផ្នែកនិងតំបន់រណបនៅបរទេស)
- អៀរឡង់ខាងជើង ***
- ន័រវែស (រួមទាំងផ្នែកនិងតំបន់រណបនៅបរទេស)
- ប៉ូឡូញ
- ព័រទុយហ្គាល់ (រួមទាំងផ្នែកនិងតំបន់រណបនៅបរទេស)
- រ៉ូម៉ានី
- រុស្ស៊ី****
- សាំងម៉ារ៉ាំង
- ស៊ែប្រ
- ស្លូវ៉ាគី
- ស្លូវេនី
- អេស្ប៉ាញ
- ស៊ុយអែត
- ស្វីស
- តាហ្ស៊ីគីស្ថាន
- តួគី
- តួកមេនីស្ថាន
- អ៊ុយក្រែន
- អូសបេគីស្ថាន
- បូរី៉ាទីកង់

**Macau S.A.R **មានសិទ្ធិគ្រប់គ្រាន់**ហើយត្រូវបានបញ្ចូលក្នុងបញ្ជីខាងលើ ហើយសម្រាប់តែគោលបំណងកម្មវិធី DV នេះប៉ុណ្ណោះ។ បុគ្គលដែលកើតនៅតំបន់ Macau S.A.R ត្រូវទាញយកសិទ្ធិរបស់ខ្លួនពីប្រទេសព័រទុយហ្គាល់។

*** សម្រាប់តែគោលបំណងកម្មវិធី DV ប៉ុណ្ណោះ អៀរឡង់ខាងជើងត្រូវបានចាត់ទុកដោយឡែក។ **អៀរឡង់ខាងជើងមានសិទ្ធិគ្រប់គ្រាន់**ហើយត្រូវបានបញ្ចូលទៅក្នុងចំណោមតំបន់ដែលមានសិទ្ធិគ្រប់គ្រាន់ផ្សេងទៀត។

****បុគ្គលដែលកើតនៅបណ្តាប្រជុំកោះហាបូមី ស៊ីកូតាន គូណាស៊ីរី និងអេតូរូហ្វូននឹងយកទៅតាមប្រទេសជប៉ុន។ បុគ្គលដែលកើតនៅខេត្តសាខាលីនខាងត្បូងនឹងយកប្រទេសកំណើតទៅតាមប្រទេសរុស្ស៊ី។

## <u>តំបន់អាមេរិកខាងជើង</u>

- បាហាម៉ាស (The Bahamas)

ក្នុងតំបន់អាមេរិកខាងជើង ប្រជាជនដើមរបស់កាណាដានិងម៉ិចស៊ិក**គ្មាន**សិទ្ធិចុះឈ្មោះនៅក្នុងកម្មវិធី DV នៅឆ្នាំនេះឡើយ។

## <u>តំបន់អូសេអានី</u>

- អូស្ត្រាលី (រួមទាំងផ្នែកនិងតំបន់រណបនៅបរទេស)
- ហ្វីជី
- គីរីបាទី
- តំបន់កោះម៉ាហ្សាល
- មីក្រូណេស៊ី
- រដ្ឋសហព័ន្ធណូរូ
- ណូវែលសេឡង់ (រួមទាំងផ្នែកនិងតំបន់រណបនៅបរទេស)
- ប៉ាឡូ
- ប៉ាពូនូវែលហ្គីណេ
- សាម៉ូអា
- តំបន់កោះសូលូម៉ង់
- តុងហ្គា
- ទូវ៉ាលូ
- វ៉ានូទូ

## <u>តំបន់អាមេរិកខាងត្បូង អាមេរិកកណ្តាល និងតំបន់ការ៉ាអ៊ីប</u>

- អង់ទីហ្គានិងបាប៊ុយដា
- នីការ៉ាហ្គា



SENSITIVE BUT UNCLASSIFIED

- អាហ្សង់ទីន
- បាបាដុស
- បេលី
- បូលីវី
- ស៊ីលី
- កូស្តារីកា
- ដូមីនីក អេក្វាទ័រ
- ហ្គ្រើណាដ
- ហ្គាតេម៉ាឡា
- ហ្គីយ៉ាន
- ប៉ាណាម៉ា
- ប៉ារ៉ាហ្គាយ
- ប៉េរូ
- សាំងគិតស៍និងណេវីស
- សាំងលូស៊ី
- សាំងវិនសង់ត៍និងហ្គ្រើណាដង់
- សូរីណាម
- ទ្រីនីដាដនិងតូបាហ្គោ
- អ៊ុយរូហ្គាយ

**ប្រទេសនៅក្នុងតំបន់នេះមានប្រជាជនដើមដែលគ្មានសិទ្ធិចុះឈ្មោះនៅក្នុងកម្មវិធី DV នៅឆ្នាំនេះ៖**

- ប្រេស៊ីល
- កូឡុំប៊ី
- គុយបា
- សាធារណរដ្ឋដូមីនីក
- អែលសាល់វ៉ាឌ័រ
- ហៃទី
- ហុងឌូរ៉ាស
- ហ្សាម៉ាអ៊ីក
- ម៉ិកស៊ិក
- វ៉េណេស៊ុយអេឡា